**សំណៅកែសម្រួលមិនទាន់ផ្សព្វផ្សាយ**

ចែកចាយ៖ ទូទៅ
១៧ សីហា ២០១៧

អត្ថបទដើម៖ ភាសាអង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទីសាមសិបប្រាំមួយ**
១១-២៩ កញ្ញា ២០១៧
របៀបវារៈចំណុច២ និងចំណុច១០
**របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ**

**ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព**

# តួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយឧបត្ថម្ភដល់រដ្ឋាភិបាល និង ប្រជាជនកម្ពុជា ដើម្បីលើកស្ទួយ និង ការពារសិទ្ធិមនុស្ស*

## របាយការណ៍របស់អគ្គលេខាធិការ

*សេចក្តីសង្ខេប*

របាយការណ៍នេះ រួមបញ្ចូលសេចក្តីបរិយាយលម្អិតអំពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) ប្រចាំកម្ពុជា ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៧។

នៅក្នុងអំឡុងពេលនេះ បានសម្គាល់ឃើញការបន្តមានភាពតានតឹងផ្នែកនយោ-បាយ ការធ្លាក់ចុះនៃលំហសង្គមស៊ីវិល ប៉ុន្តែក៏សម្គាល់ឃើញមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងការសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រផងដែរ។ នៅខាងចុងនៃរយៈពេលនេះ មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ ប្រកបដោយសន្តិភាពនិងរៀបរយ។ ការិយាល័យឧត្តមស្នង

ការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តកម្មវិធីរបស់ខ្លួនខាងសហប្រតិបត្តិការផ្នែកបច្ចេកទេសក្នុងវិស័យសំខាន់ៗមួយចំនួន សម្រាប់ការការពារសិទ្ធិមនុស្ស ជាពិសេស ការគាំទ្រដល់សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ និងសេរីភាពជាមូលដ្ឋានទាំងអស់ដែលពាក់ព័ន្ធ ការពង្រឹងនីតិរដ្ឋ និងការលើកកម្ពស់សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

---------------------------------

* របាយការណ៍នេះ កំពុងត្រូវបានដាក់បញ្ជូនយឺត ដើម្បីទុកពេលវេលាច្រើនជាអតិបរមាសម្រាប់រដ្ឋជាសមាជិក ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដាក់ស្នើព័ត៌មានទាំងឡាយដែលពាក់ព័ន្ធ។

## I. សេចក្តីផ្តើម

១. របាយការណ៍នេះ ត្រូវបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ដោយអនុលោមតាមសេចក្តីសម្រេចចិត្តលេខ៣០/២៣ និងបរិយាយអំពីសកម្មភាពរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យOHCHR) ប្រចាំកម្ពុជា ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ។

២. អាណត្តិខាងដើម ត្រូវបានកំណត់ដោយសេចក្តីសម្រេចចិត្តលេខ១៩៩៣/៦ របស់គណៈកម្មការសិទ្ធិមនុស្សថា ការងាររបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំកម្ពុជា ត្រូវបានដឹកនាំដោយសេចក្តីសម្រេចចិត្តលេខ(៣០/២៣)ដែលមានរយៈពេលពីរឆ្នាំ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលរយៈពេលពីរឆ្នាំនេះមានចែងនៅក្នុងអនុស្សារណៈយោគយល់គ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជា[1] និងអាណត្តិសកលរបស់ឧត្តមស្នងការ ដូចដែលមានចែងក្នុងសេចក្តីសម្រេចចិត្តលេខ៤៨/១៤១ របស់មហាសន្និបាត និងសេចក្តីប្រកាសទីក្រុងវីយែន និងកម្មវិធីសកម្មភាពដែលបន្តមានពីមហាសន្និបាតពិភពលោកឆ្នាំ១៩៩៣ ស្តីពីសិទ្ធិមនុស្ស ស្ថិតក្រោមគោលការណ៍សំខាន់ៗដែលមានវិសាលភាពទូលំទូលាយ នៃធម្មនុញ្ញសហប្រជាជាតិ។ អាណត្តិនេះត្រូវបានឲ្យដឹងតាមរយៈសេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សអន្តរជាតិស្តីពីកម្ពុជា ព្រមទាំងការប្តេជ្ញាចិត្តជាសកលក្រោមរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

៣. កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សរបស់កម្ពុជា បានបន្តមានក្នុងសន្ទុះប្រមាណជា ៧ ភាគរយនៅក្នុងអំឡុងឆ្នាំ២០១៦ ហើយសន្ទុះស្ទើរតែដូចគ្នានេះ ត្រូវបានគេរំពឹងថានឹងមានសម្រាប់ឆ្នាំ២០១៧។ [2] កម្ពុជាបានចាកផុតពីឋានៈជាប្រទេសដែលមានប្រាក់ចំណូលទាបកម្រិតមធ្យម

---

[1] អនុស្សរណៈបច្ចុប្បន្ននេះ ត្រូវបានចុះហត្ថលេខាក្នុងខែធ្នូ ឆ្នាំ២០១៦ គ្របដណ្តប់រយៈពេលចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

[2] សូមមើលធនាគារអភិវឌ្ឍន៍អាស៊ី *ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៧៖ ការចាកផុតបញ្ហាប្រឈមខាងប្រាក់ចំណូលមធ្យមកម្រិតទាប* (មេសា ២០១៧) អាចរកបានពី www.adb.org/sites/default/files/publication/237761/ado-2017.pdf និង ទិដ្ឋភាពទូទៅរបស់កម្ពុជា គិតត្រឹមខែមេសា ២០១៧ (ធនាគារពិភពលោក) អាចរកបានពី www.worldbank.org/en/country/cambodia/overview.

(LMIC) នៅក្នុងឆ្នាំ២០១៦។ សន្ទស្សន៍ពហុវិមាត្រនៃភាពក្រីក្រនិងសន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស បានបង្ហាញពីការកាត់បន្ថយភាពក្រីក្រយ៉ាងច្រើន [3] បើទោះជានៅមានបញ្ហាប្រឈមដែលរួមមានវិសមភាពនៃប្រាក់ចំណូល ការបែងចែក ឬគម្លាតទីក្រុង-ជនបទ និងភាពងាយរងគ្រោះដែលជាភាពអសកម្មតិចតួចក្តី។ ប្រជាជនប្រហែលជា ៤,៥ លាននាក់ (ច្រើនជាង ២៨ ភាគរយនៃប្រជាជនសរុប) បានចាកផុតពីភាពក្រីក្រក្នុងកម្រិតមួយផិតផើយ ហើយដែលអាចចាត់ថា "ជិតក្រ ឬក្បែរក្រ"។[4] ការដោះស្រាយ "ខ្លឹមនៃភាពក្រីក្រនិងភាពងាយរងគ្រោះ ត្រូវបានកំណត់ដោយរដ្ឋាភិបាលនៅឆ្នាំ២០១៧ ថា ជាបញ្ហាមួយក្នុងចំណោមបញ្ហាប្រឈមពហុវិស័យធំៗនៅថ្ងៃខាងមុខ។ [5] រួមគ្នាជាមួយសមាជិកដទៃទៀត នៃក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ការិយាល័យOHCHR បានចាប់ផ្តើមធ្វើ "ការសិក្សាអំពីភាពងាយរងគ្រោះ" សំដៅគាំទ្រដល់រាជរដ្ឋាភិបាល ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន។

៤. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ បានឃើញកម្រិតនៃភាពតានតឹងផ្នែកនយោបាយកើតមានស្របគ្នាទៅនឹងចំណាត់ការរបស់តុលាការប្រឆាំងនឹងសមាជិកគណបក្សប្រឆាំង។ មានចំណាត់ការរបស់តុលាការយ៉ាងហោចណាស់ក៏ ២៣ ដែរ ដែលត្រូវបានចាត់ ដោយបានដំណើរការឡើងវិញ ឬបានបន្តធ្វើឡើងប្រឆាំងនឹងតួអង្គគណបក្សប្រឆាំងនៅថ្នាក់ជាតិ និងនៅថ្នាក់មូលដ្ឋាន ដែលនាំឲ្យមានការផ្តន្ទាទោសព្រហ្មទណ្ឌថ្មីចំនួន ១០ ករណី។ សកម្មភាពនេះគឺផ្ទុយទៅនឹងស្មារតីដែលខួបទីម្ភៃប្រាំនៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយទូលំទូលាយនៃវិវាទនៅកម្ពុជា (កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស) បានប្រារព្ធធ្វើនៅខែតុលាឆ្នាំ២០១៦។ កិច្ចព្រមព្រៀងនេះ បានត្រួសត្រាយផ្លូវសម្រាប់សន្តិភាពដ៏យូរអង្វែងនៅក្នុងប្រទេសកម្ពុជា និងបានបង្កើតជាផែនគ្រឹះនៃរដ្ឋធម្មនុញ្ញកម្ពុជា។ នៅក្នុងសេចក្តីថ្លែងការណ៍នាឱកាសនោះ រាជរដ្ឋាភិបាលកម្ពុជា បានអះអាងជាថ្មី អំពីការប្រាថ្នាចង់បានអធិបតេយ្យភាព បូរណភាពទឹកដី និងសិទ្ធិស្វ័យសម្រេច ដោយរំលេចឲ្យឃើញអំពីការរងទុក្ខវេទនារបស់ប្រជាជនកម្ពុជា បណ្តាលមកពីសង្គ្រាមក្នុងរយៈកាលកន្លងមក។ ទស្សនៈនេះ ដែលក្រោយមក ត្រូវបានបង្កើតទៅជាឯកសារផ្លូវការដែលហៅថា ក្រដាសពណ៌ស ដែលចេញនៅខែមេសាឆ្នាំ២០១៧[6] និងដែលបានធ្វើម្តងទៀត នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះទាំងមូល។ នៅក្នុងឱកាសរំលឹកខួបនេះ អង្គការសង្គមស៊ីវិលបានសង្កត់ធ្ងន់អំពីបទប្បញ្ញត្តិសំខាន់ៗនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពទាក់ទងនឹងសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ហើយនិងភាពផុយស្រួយនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដោយសារតែកង្វះប្រសិទ្ធភាពនៃការបែងចែកអំណាចក្នុងរដ្ឋាភិបាល។

៥. ក្នុងរយៈពេលមួយឆ្នាំពេញនេះ ការិយាល័យOHCHR បានបន្តសកម្មភាពសហប្រតិបត្តិការផ្នែកបច្ចេកទេសជាច្រើនជាមួយតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គណៈកម្មាធិការសិទ្ធិ

---

[3] សូមមើលកម្មវិធីអភិវឌ្ឍសហប្រជាជាតិ *របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០១៦ ៖ ការអភិវឌ្ឍមនុស្សសម្រាប់គ្រប់គ្នា* (ទីក្រុងញូវយ៉ក ២០១៦)

[4] សូមមើលទិដ្ឋភាពទូទៅរបស់កម្ពុជា (កំណត់ជើងទំព័រលេខ ២ ខាងលើ)

[5] សូមមើលរបាយការណ៍ប្រជុំនៃបណ្តាញក្រុមការងារបច្ចេកទេសក្នុងខែកុម្ភៈ ដែលអាចរកបានពី www.cdc-crdb.gov.kh/cdc/twg_network/twg_network_february_2017/documents/twgreport.pdf.

[6] សូមមើល www.mfaic.gov.kh/wp-content/uploads/2017/04/Ministry-of-Foreign-Affair-201704-388.pdf.

មនុស្សកម្ពុជារបស់រដ្ឋាភិបាល ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ និងអ្នកកាន់ភារកិច្ចដទៃទៀត ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ព្រមទាំងជាមួយសង្គមស៊ីវិល និងម្ចាស់សិទ្ធិ។ ការិយាល័យOHCHR បានបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជា។ ការិយាល័យOHCHR បានតាមឃ្លាំមើលបរិយាកាសសិទ្ធិមនុស្ស នៅពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខែមិថុនា ឆ្នាំ២០១៧ ដូចដែលការិយាល័យOHCHR ធ្លាប់មាននៅរៀងរាល់ពេលនៃការបោះឆ្នោត ចាប់តាំងពីការិយាល័យនេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៣។

## II. ការការពារលំហរប្រជាធិបតេយ្យ

៦. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍រហូតដល់ការបោះឆ្នោតក្នុងខែមិថុនា មានកង្វល់អំពីសិទ្ធិមនុស្សជាច្រើនទាក់នឹងការប្រព្រឹត្តទៅលើគណបក្សប្រឆាំង អង្គការសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្ស និងប្រព័ន្ធផ្សព្វផ្សាយ។ កង្វល់ទាំងនោះ បានប៉ះពាល់ដល់បរិយាកាសដែលក្នុងនោះ ការិយាល័យOHCHR បានប្រតិបត្តិការ និងប៉ះពាល់ដល់សកម្មភាពការងាររបស់ខ្លួន។

៧. ការិយាល័យOHCHR បានធ្វើការជាមួយអ្នកកាន់ភារកិច្ច និងម្ចាស់សិទ្ធិ ដើម្បីជួយការពារដល់លំហរលទ្ធិប្រជាធិបតេយ្យ ជាពិសេស ដើម្បីផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូបក្នុងការអនុវត្តសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈប្រកបដោយអត្ថន័យ។ ការិយាល័យOHCHR បានធ្វើការងារការពារលំហរសម្រាប់សង្គមស៊ីវិល រាប់បញ្ចូលទាំងអង្គការសិទ្ធិមនុស្សផងដែរ។ ការិយាល័យOHCHR បានផ្តោតសកម្មភាពរបស់ខ្លួនទៅលើការលើកកម្ពស់ ការគោរពដល់កិច្ចការពារសិទ្ធិសេរីភាពក្នុងការជួបប្រជុំ ក្នុងការបង្កើតសមាគម ក្នុងការបញ្ចេញមតិ និងយោបល់ ព្រមទាំងលើកិច្ចការពារអ្នកការពារសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស ឆ្នាំ១៩៩៩។[7]

៨. ដំណើរការប្រជាធិបតេយ្យ ត្រូវបានប៉ះពាល់ដោយនីតិវិធីតុលាការ និងវិធានការផ្សេងៗដែលដៅទៅលើសមាជិកគណៈបក្សប្រឆាំង ឬអ្នកដែលត្រូវបានគេយល់ថាប្រឆាំងនឹងគណបក្សកាន់អំណាច។ ថ្នាក់ដឹកនាំទាំងពីរនៃគណបក្សប្រឆាំងដ៏ធំមួយ គឺគណបក្សសង្គ្រោះជាតិកម្ពុជា លោក កឹម សុខា និងលោក សម រង្ស៊ី ត្រូវបានតុលាការកោះហៅឲ្យចូលខ្លួន ចោទប្រកាន់ ឬផ្តន្ទាទោសពាក់ព័ន្ធនឹងករណីចំនួន១០ ដែលភាគច្រើនទាក់ទងនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងការញុះញង់។ កាលពីចុងឆ្នាំ២០១៦ សមាជិកសភារបស់គណបក្សប្រឆាំងចំនួន ២ រូបផ្សេងទៀត ត្រូវបានផ្តន្ទាទោស និងកាត់ទោសឲ្យជាប់ពន្ធនាគារ ម្នាក់ជាប់ពន្ធនាគារ ៣០ ខែ និងម្នាក់ទៀត ជាប់ ៧ ឆ្នាំ។ អភ័យឯកសិទ្ធិសភារបស់ពួកគេ មិនត្រូវបានដកឡើយ ពីព្រោះដោយបានសន្មត់ថា ត្រូវបានចាប់ខ្លួនក្នុងបទល្មើសជាក់ស្តែង។ សមាជិកគណបក្សប្រឆាំងចំនួនបីរូប ត្រូវបានផ្តល់សិទ្ធិជ្រកកោននៅក្រៅប្រទេស ។

[7] សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គម ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលទទួលស្គាល់ជាសកល (សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ 53/144 ឧបសម្ព័ន្ធ)។

៩. ដោយសារតែមានការប៉ុនប៉ងចាប់ខ្លួនលោក កឹម សុខា ដោយគ្មានដីកាកាលពីខែឧសភា ឆ្នាំ ២០១៦ លោកក៏បានបង្ខាំងខ្លួនឯងអស់រយៈពេលជិតប្រាំពីរខែ នៅក្នុងទីស្នាក់ការកណ្តាលរបស់គណបក្សសង្គ្រោះជាតិ ដើម្បីគេចចេញពីការចាប់ខ្លួននេះ។ ដោយមានការកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេលប្រាំខែ កាលពីខែកញ្ញា ឆ្នាំ២០១៦ ពីបទបដិសេធមិនបង្ហាញខ្លួនក្នុងនាមជាសាក្សី លោកទទួលក៏បានការលើកលែងទោសកាលពីខែធ្នូ ឆ្នាំ២០១៦ ដែលតាមរយៈនេះ លោកបានចេញពីទីស្នាក់ការកណ្តាលរបស់គណបក្ស។ ក្នុងពេលជាមួយគ្នានេះ ចាប់តាំងពីចុងឆ្នាំ២០១៥ មក លោក សម រង្ស៊ី នៅតែស្ថិតក្នុងការនិរទេសន៍ដោយស្ម័គ្រចិត្តនៅក្រៅប្រទេស ដើម្បីគេចពីការចាប់ខ្លួន។ ក្នុងខែតុលា ឆ្នាំ២០១៦ ទីស្តីការគណៈរដ្ឋមន្ត្រី បានណែនាំឲ្យនាយកដ្ឋានអន្តោប្រវេសន៍ចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីរារាំងលោកមិនឲ្យវិលត្រឡប់ចូលមកកម្ពុជាវិញ រហូតដល់សេចក្តីណែនាំនេះត្រូវបានលុបចោលវិញកាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧។ កាលពីដើមខែវិច្ឆិកា ឆ្នាំ២០១៦ អង្គរក្សបីនាក់របស់លោកនាយករដ្ឋមន្ត្រី ដែលអង្គរក្សទាំងនោះពាក់ព័ន្ធនឹងការវាយដំយ៉ាងសាហាវទៅលើសមាជិកសភារបស់គណបក្សប្រឆាំងទាំងពីររូបកាលពីឆ្នាំ២០១៥ ត្រូវបានដោះលែងក្រោយពីបានជាប់ពន្ធនាគារមួយឆ្នាំក្នុងចំណោមបួនឆ្នាំ ក្នុងនោះទោសជាប់ពន្ធនាគារ ៣ ឆ្នាំទៀត ត្រូវបានព្យួរ។ ក្រោយមកក្នុងខែនោះដែរ ពួកគេត្រូវបានដំឡើងឋានៈទៅជាវរៈសេនីយ៍ឯក និងឧត្តមសេនីយ៍ផ្កាយមួយ។ ផ្ទុយទៅវិញ សមាជិក ឬអ្នកគាំទ្រគណបក្សប្រឆាំងចំនួន ១៤ នាក់ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទកុប្បកម្ម បន្ទាប់ពីបានអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួនក្នុងការបញ្ចេញមតិ និងក្នុងការបង្កើតសមាគម ដោយការចូលរួមក្នុងបាតុកម្មមួយក្នុងឆ្នាំ២០១៤។[8] ពួកគេត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ឆ្នាំ ដល់ ២០ ឆ្នាំ កាលពីឆ្នាំ២០១៥ ហើយបណ្តឹងឧទ្ធរណ៍របស់ពួកគេត្រូវបានបដិសេធកាលពីឆ្នាំ២០១៧។

១០. វិសោធនកម្មដ៏ចម្រូងចម្រាស់នៃច្បាប់ស្តីពីគណបក្សនយោបាយ ដែលច្បាប់នេះមានបទប្បញ្ញត្តិជាច្រើនមិនស្របទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជានោះ ត្រូវបានអនុម័តយ៉ាងលឿនកាលពីខែកុម្ភៈ ឆ្នាំ២០១៧ ដោយមិនទុកពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើការពិគ្រោះយោបល់ជាសាធារណៈ។ ក្នុងចំណោមបទប្បញ្ញត្តិទាំងឡាយ បទប្បញ្ញត្តិវិសោធនកម្មទាំងនេះអនុញ្ញាតឲ្យមានវិធានការរដ្ឋបាលដើម្បីព្យួរដោយមិនមានពេលកំណត់ច្បាស់លាស់ទៅលើសកម្មភាពគណបក្សនយោបាយដោយគ្មាននីតិវិធីច្បាប់ត្រឹមត្រូវ និងធ្វើការហាមឃាត់ជនដែលត្រូវបាន ផ្តន្ទាទោសណាមួយ រាប់បញ្ចូលទាំងពីបទល្មើសមជ្ឈឹម[9] មិនឲ្យដឹកនាំគណបក្សនយោបាយ។ ការិយាល័យOHCHR បានផលិតនិងចែករំលែកជាមួយរាជរដ្ឋាភិបាលនូវសេចក្តីវិភាគពិស្តាររបស់ខ្លួនទៅលើច្បាប់វិសោធនកម្មនេះ ពាក់ព័ន្ធនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។[10] នៅចំពោះមុខនៃអនុម័តច្បាប់នេះ លោក សម រង្ស៊ី និងសមាជិកសភាគណបក្សប្រឆាំងផ្សេងទៀត

[8] សូមមើលរបាយការណ៍ A/HRC/33/39 កថាខណ្ឌ ៧។

[9] មាត្រា៤៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលថា៖ បទល្មើសជាបទមជ្ឈឹម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលលើសពីប្រាំមួយថ្ងៃ ប៉ុន្តែមិនលើសពីប្រាំឆ្នាំ។

[10] សូមមើល http://cambodia.ohchr.org/sites/default/files/Analysis%20on%20the%20Amended%20Law%20on%20Political%20Parties%20%28FINAL-EN%29.pdf.

ដែលគេផ្តន្ទាទោស បានលាលែងចេញពីជួរថ្នាក់ដឹកនាំគណបក្ស ប្រយោជន៍កុំឲ្យគេប្រើប្រាស់ឋានៈរបស់ពួកគេ ដើម្បីរំលាយគណបក្សរបស់ខ្លួន។

១១. ក្នុងខែមេសា ក្រុមប្រឹក្សាភិបាលនៃសហភាពអន្តរសភា បានចេញសម្រេចមួយស្តីពីករណីសមាជិកសភាកម្ពុជាទាំង ១៥ រូប ដោយលើកឡើងថា ខ្លួននៅតែមាន "កង្វល់យ៉ាងខ្លាំង" អំពី "ការរំលោភយ៉ាងធ្ងន់ធ្ងរ" ទៅលើសេរីភាពទាំងឡាយរបស់សមាជិកសភា "គណបក្សប្រឆាំងមួយផ្នែកធំ" ហើយបានចាត់ទុកថា "សមាជិកសភាទាំងនោះ កំពុងតែត្រូវបានគេរារាំងមិនឲ្យបំពេញតួនាទីក្នុងនាមជាសមាជិកសភា និងសមាជិករបស់គណបក្សប្រឆាំងឲ្យមានប្រសិទ្ធភាពដោយសេរី ដោយគ្មានការភ័យខ្លាចពីការធ្វើទុក្ខបុកម្នេញ"។[11]

១២. ករណីបាញ់សំលាប់លោក កែម ឡី ដែលជាអ្នកវិភាគនយោបាយដ៏ល្បីឈ្មោះ ជាសកម្មជនសង្គម និងជាស្ថាបនិកមួយរូបនៃគណបក្សប្រជាធិបតេយ្យមូលដ្ឋាន កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ បានធ្វើឲ្យប្រទេសនេះមានការតក់ស្លុតយ៉ាងខ្លាំង។ ក្នុងចំណោមមនុស្សម្នាច្រើនរាប់ពាន់នាក់ដែលបានប្រមូលផ្តុំគ្នាជាសាធារណៈដើម្បីកាន់ទុក្ខសពរបស់គាត់ មនុស្សជាច្រើនបានចាត់ទុកការសម្លាប់នេះជាអំពីឃាតកម្ម និងភ័យខ្លាចកើតមានការសម្លាប់តទៅទៀត។ ចំពោះមុខការគំរាមកំហែងនេះ ប្រពន្ធនិងកូនទាំងប្រាំរបស់លោក ក៏បានស្វែងរកសិទ្ធិជ្រកកោននៅក្រៅប្រទេស។ បុរសម្នាក់ត្រូវបានគេចាប់ខ្លួន មិនយូរប៉ុន្មានក្រោយពីការបាញ់ប្រហារនេះ ហើយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិតក្នុងខែមីនា ឆ្នាំ២០១៧ ស្ថិតក្នុងកាលៈទេសៈគួរឲ្យមន្ទិលសង្ស័យជាច្រើនទាក់ទងនឹងភាពពិតនៃចម្លើយសារភាពរបស់គាត់ចំពោះករណីឃាតកម្មនេះ និងហេតុផលដែលបានប្រកាស។ អ្នកវិភាគនយោបាយម្នាក់ទៀត គឺលោក គឹម សុខ បានស្ថិតក្នុងការឃុំខ្លួនជាបណ្តោះអាសន្នតាំងពីខែកុម្ភៈ ឆ្នាំ២០១៧ ពីបទញុះញង់ និងបទបរិហារកេរ្តិ៍ ក្រោយពីបានអះអាងថា រដ្ឋាភិបាលនៅពីក្រោយករណីឃាតកម្មនេះ។

១៣. បុគ្គលិកចំនួនបួននាក់ របស់សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) និង អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានស្ថិតក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន តាំងពីខែមេសា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ទើបមានការដោះលែងឲ្យពួកគេនៅក្រៅឃុំ។ ពួកគេនៅតែជាប់ចោទពីបទសូកប៉ាន់សាក្សី ឬបទសមគំនិតក្នុងអំពើសូកប៉ាន់ ទាក់ទងនឹងបណ្តឹងព្រហ្មទណ្ឌមួយ ក្នុងចំណោមបណ្តឹងព្រហ្មទណ្ឌទាំងឡាយដែលត្រូវបានធ្វើឡើងប្រឆាំងនឹងលោក សុខា (សូមអានរបាយការណ៍លេខ A/HRC/33/39, កថាខណ្ឌទី១១)។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ ក្រុមការងារស្តីពីការឃុំខ្លួនតាមទំនើងចិត្ត បានចាត់ទុកការឃុំខ្លួនអ្នកទាំងនេះថាជា "ការឃុំខ្លួនតាមទំនើងចិត្ត" ជាការបដិសេធសេរីភាពជាមូលដ្ឋានរបស់ពួកគេ និងការរំលោភធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ពួកគេក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។

១៤. ការតវ៉ារបស់សង្គមស៊ីវិល (ការប្រមូលផ្តុំដែលត្រូវហៅថា "ថ្ងៃច័ន្ទព៌ណខ្មៅ") ដែលអំពាវនាវឲ្យមានការដោះលែង ជាបន្ទាន់នូវសមាជិកខាងលើនៃសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍

[11] សូមមើលសេចក្តីសម្រេចដែលអនុម័តដោយក្រុមប្រឹក្សាភិបាលនៃសហភាពអន្តរសភា (IPU) នាសម័យប្រជុំលើកទី២០០ របស់ខ្លួន (ទីក្រុងដាកា ខែមេសា ឆ្នាំ២០១៧ ដែលអាចរកបានពី www.ipu.org/hr-e/200/cmbd27.pdf.

នៅកម្ពុជា (ADHOC) និងអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលត្រូវបានគេបំបែកដោយបង្ខំ។ អ្នកស្រី ទេព វន្នី ជាសកម្មជនសិទ្ធិដីធ្លីដ៏ល្បីល្បាញ ដែលបានចូលរួមយ៉ាងសកម្មតាំងពីដំបូងក្នុងការប្រមូលផ្តុំទាំងនេះ បានជាប់ឃុំតាំងពីខែសីហា ឆ្នាំ ២០១៦ ក្រោយពីមានការផ្តន្ទាទោសដោយផ្អែកលើករណីផ្សេងៗ ដែលបានធ្វើឡើងកាលពីមុនប្រឆាំងនឹងរូបគាត់ ដោយសារតែគាត់អនុវត្តសេរីភាពក្នុងការបញ្ចេញមតិ។ ក្នុងករណីទាំងនោះ និងករណីដទៃផ្សេងទៀត អាជ្ញាធររដ្ឋ តែងតែបានចោទប្រកាន់ជារឿយៗថា ជាការប៉ុនប៉ងធ្វើសកម្មភាព ដែលគេហៅថា "បដិវត្តន៍ពណ៌"។

១៥. ករណីទាំងនេះ បានធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សហគមន៍នៃអ្នកធ្វើការសិទ្ធិមនុស្ស និងសង្គមស៊ីវិលយ៉ាងទូលំទូលាយ។ ការិយាល័យOHCHR បានឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សនៅក្នុងបរិយាកាសមុនការបោះឆ្នោត - ការអនុវត្ត និងការរឹតត្បិតទៅលើសេរីភាពជាមូលដ្ឋាន និងចំនួនដែលកំពុងកើនឡើងនៃចំណាត់ការតាមផ្លូវតុលាការ។ ចាប់តាំងពីឆ្នាំកន្លងទៅ មន្រ្តីគណបក្សប្រឆាំងនៅតាមមូលដ្ឋាន ត្រូវបានគេកំណត់ ជាគោលដៅយ៉ាងខ្លាំង រីឯអ្នកធ្វើការងារសិទ្ធិមនុស្ស និង/ឬអ្នកឃ្លាំមើលការបោះឆ្នោតឯករាជ្យ ត្រូវបានរដ្ឋាភិបាលចោទប្រកាន់ថា មានភាពលំអៀង ។

១៦. វាស្ថិតក្នុងបរិយាកាសនេះហើយ ដែលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់លើកទី ៤ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧។ មន្រ្តីថ្នាក់ខ្ពស់ជាច្រើន បានអះអាងអំពីភាពស្មោះត្រង់របស់យោធាទៅលើគណបក្សកាន់អំណាច ហើយបានព្រមានថា អំពីហឹង្សា - សង្គ្រាមស៊ីវិល - នឹងកើតមានឡើង ប្រសិនបើគណបក្សប្រឆាំងឈ្នះ ឬមានការតវ៉ាប្រឆាំងនឹងលទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នោះ។ មិនយូរប៉ុន្មាន មុនថ្ងៃបោះឆ្នោត មន្រ្តីជាន់ខ្ពស់នៃក្រសួងមហាផ្ទៃបានព្រមានថា អង្គការសង្គមស៊ីវិលមួយចំនួន បានស្ថិតក្រោមការតាមដានដោយសារតែពួកគេផ្តល់ជំនួយខុសច្បាប់ទៅឲ្យគណបក្សប្រឆាំង ហើយអាចនឹងត្រូវប្តឹងទៅតុលាការក្រោយពីការបោះឆ្នោត ដែលក្រោយមកមានការទទួលស្គាល់ថា នេះគឺជាការគំរាមកំហែងប្រឆាំងមួយនឹងអង្គការទាំងនេះ។ ការស៊ើបអង្កេតលើអង្គការសង្គមស៊ីវិលមួយចំនួន ជាការពិតណាស់ ត្រូវបានធ្វើឡើងដោយក្រសួងមហាផ្ទៃនៅថ្ងៃទី២៩ ខែមិថុនា បន្ទាប់ពីមានការណែនាំពីលោកនាយករដ្ឋមន្រ្តី។

១៧. នៅថ្ងៃបោះឆ្នោត ការិយាល័យOHCHR បានធ្វើការឃ្លាំមើលសិទ្ធិមនុស្សនៅទីក្រុងភ្នំពេញ និងនៅខេត្តចំនួន ៦ ទូទាំងប្រទេស។ បញ្ជីឈ្មោះអ្នកបោះឆ្នោតថ្មី ដែលត្រូវរៀបចំឡើងកាលពីចុងឆ្នាំ២០១៦ ត្រូវបានអ្នកឃ្លាំមើលការបោះឆ្នោត ចាត់ទុកថា មានភាពត្រឹមត្រូវជាង ៩៨% ដែលនេះគឺជាភាពប្រសើរមួយដ៏គួរឲ្យកត់សំគាល់ ធៀបនឹងស្ថានភាពនៅក្នុងឆ្នាំ២០១៣។ ប្រជាពលរដ្ឋកម្ពុជា បានចេញទៅបោះឆ្នោតមានចំនួនខ្ពស់ (៩០.៣៧% ក្នុងចំណោមអ្នកបោះឆ្នោតដែលបានចុះឈ្មោះ បានបោះឆ្នោត) ហើយខុសពីការបោះឆ្នោតពីមុនៗ ពុំមានអ្នកបោះឆ្នោតណាម្នាក់បានអះអាងថា ពួកគេត្រូវបានគេរារាំងមិនឲ្យបោះឆ្នោតនោះ ឡើយ។ ការបោះឆ្នោតបានប្រព្រឹត្តទៅដោយសន្តិវិធី។ លទ្ធផលបណ្តោះអាសន្ន ដែលទទួលយកពីគ្រប់គណបក្សទាំងអស់ បានឆ្លុះបញ្ចាំងពីចំនួនដ៏ច្រើនលើសលុបដែលគណបក្សកាន់អំណាចនៅតែបន្តទទួលបាន ប៉ុន្តែក៏បានឆ្លុះបញ្ចាំងផងដែរ អំពីការកើនឡើងដ៏ច្រើនដែលគណបក្សប្រឆាំងទទួល

បាន ។ បណ្ដឹងមួយចំនួន ត្រូវបានធ្វើឡើង និងដោះស្រាយទាំងអស់ ហើយលទ្ធផលក៏ត្រូវបានប្រកាស នៅថ្ងៃទី២៥ ខែមិថុនា។

១៨. ក្នុងរយៈពេលមួយឆ្នាំនេះ ការិយាល័យOHCHR បានសង្កេតឃើញមានករណីសរុបចំនួន ១១៣ ករណី ដែលទាក់ទងនឹងការយាយី ឬការគំរាមកំហែង ការចាប់ខ្លួន និងការឃុំខ្លួនតាមទំនើងចិត្ត ការរំលោភលើបូរណភាពរូបកាយ និងការសម្លាប់ និទណ្ឌភាព និងការរំលោភលើសេរីភាពជាមូលដ្ឋាន។ ការិយាល័យ បានជួយគាំទ្រដល់ការអនុវត្តអនុសាសន៍របស់យន្តការពិនិត្យរបាយការណ៍ជាសកលតាមពេលកំណត់(UPR) ដែលប្រទេសកម្ពុជាបានទទួលយកដើម្បីធានាឲ្យមាន "ការគោរពពេញលេញ នៅក្នុងច្បាប់ និងនៅក្នុងការអនុវត្តជាក់ស្ដែងដល់សេរីភាពក្នុងការជួបប្រជុំ និងក្នុងការបង្កើតសមាគមស្របតាមច្បាប់អន្តរជាតិ"។ ខណៈដែលគ្មានរបាយការណ៍ណាមួយត្រូវបានទទួលអំពីការដាក់ទណ្ឌកម្មផ្សេងៗ ដែលគេអនុវត្តមកដល់ពេលនេះក្រោមច្បាប់ឆ្នាំ២០១៥ ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល កិច្ចប្រជុំជាច្រើនជាមួយដៃគូសង្គមស៊ីវិល និងការចុះជួបផ្ទាល់ជាមួយដៃគូរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ បានបញ្ជាក់ថា មានករណីជាច្រើនដែលក្នុងនោះ អាជ្ញាធរអនុវត្តច្បាប់មិនត្រឹមត្រូវ និងទាមទារពីអង្គការនូវព័ត៌មាន ឬសកម្មភាពផ្សេងៗដែលច្បាប់មិនបានតម្រូវ។ ការទាមទារដូចនេះ មានដូចជារបាយការណ៍សកម្មភាព សំណើរសុំឲ្យមានការជូនដំណឹង ឬការអនុញ្ញាតជាមុនសម្រាប់ធ្វើសកម្ម ឬការដាក់របាយការណ៍ហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ។

១៩. ការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធីដែលធានាការពារដោយរដ្ឋធម្មនុញ្ញ នៅតែមានការរឹតត្បិតជាបន្តបន្ទាប់។ បន្ថែមលើការបំបែកដោយបង្ខំទៅលើការប្រមូលផ្ដុំ "ថ្ងៃច័ន្ទព៌ណខ្មៅ" ការប្រមូលផ្ដុំដើម្បីប្រារព្ធខួបអន្តរជាតិផ្សេងៗ ជាញឹកញាប់ ត្រូវបានរាំងមិនឲ្យធ្វើ។ ការដើរហែរជាក្បួន ដោយសន្តិវិធីក្នុងឱកាសទិវាសិទ្ធិលំនៅដ្ឋានពិភពលោកកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ត្រូវបានបង្ក្រាបដោយហឹង្សា។ ការិយាល័យ OHCHR បានធ្វើការឆ្លើយតបទៅនឹងតម្រូវការដ៏ខ្ពស់ក្នុងចំណោមម្ចាស់សិទ្ធិ ដើម្បីពង្រឹងសមត្ថភាពក្នុងការអនុវត្តតាមច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី ឆ្នាំ២០០៩ រាប់បញ្ចូលទាំងតាមរយៈការផ្សព្វផ្សាយច្បាប់ និងគោលការណ៍ណែនាំអនុវត្តនេះ។ ការិយាល័យOHCHR បានដឹកនាំ ឬចូលរួមចំណែកក្នុងសិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពីច្បាប់នេះចំនួន៩ ដែលបានផ្សព្វផ្សាយដល់សមាជិក សង្គមស៊ីវិល និងអង្គការនៅតាមសហគម ព្រះសង្ឃ និងអ្នកសារព័ត៌មានមកពីខេត្ត-ក្រុងចំនួន១៦ បានចំនួន ៣៣២ នាក់ (ក្នុងនោះមានស្ត្រីចំនួន ៧៨ នាក់) ហើយក៏បានផលិតជាវីដេអូមួយ ដើម្បីអប់រំអំពីច្បាប់នេះ។

២០. ក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ បន្ទាប់ពីមានការប្រកាសដាក់ឲ្យប្រើប្រាស់ច្បាប់ស្ដីពីសហជីព កាលពីខែឧសភា ការិយាល័យOHCHR បានសហការរៀបចំសន្និសីទមួយស្ដីពីការពិនិត្យមើលការអនុវត្តច្បាប់នេះរយៈពេល ៦ ខែកន្លងមក ដែលមានតំណាងចំនួន ១២៩ នាក់ មកពីសមាគមនិយោជក និងសហជីព អង្គការពលកម្មអន្តរជាតិ(ILO) និងស្ថានទូតជាច្រើន បានចូលរួមពិភាក្សាអំពីបញ្ហាប្រឈម និងផ្ដល់អនុសាសន៍ផ្សេងៗ ដើម្បីធ្វើឲ្យច្បាប់នេះ ប្រសើរឡើងស្របតាមកាតព្វកិច្ចអន្តរជាតិពាក់ព័ន្ធនានា។ នៅខែធ្នូ ឆ្នាំ២០១៦ គណៈកម្មាធិការ អ្នកជំនាញរបស់អង្គការ ILO បានអនុម័តការសង្កេតឃើញមួយ ហើយបានដាក់សំណើរដោយផ្ទាល់ឲ្យអនុវត្ត

តាមអនុសញ្ញាលេខ ៨៧ ស្តីពីសេរីភាពក្នុងការបង្កើតសមាគម និងការការពារដល់សិទ្ធិក្នុងការរៀបចំ ដោយគូសបញ្ជាក់អំពីចន្លោះប្រហោះផ្សេងៗដែលត្រូវអនុវត្តតាម។

២១. រាជរដ្ឋាភិបាល បានផ្តួចផ្តើមបង្កើតសេចក្តីព្រាងច្បាប់ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា និងស្តីពីនីតិវិធី ជម្រះក្តីវិវាទការងារ។ ការិយាល័យOHCHR បានធ្វើការវិភាគទៅលើសេចក្តីព្រាងពីមុនអំពីបញ្ហាសិទ្ធិមនុស្ស។ សេចក្តីព្រាងច្បាប់បច្ចុប្បន្ន អាចនឹងរឹតត្បិតយ៉ាងខ្លាំងដល់សកម្ម ភាពស្របច្បាប់ និងការអនុវត្តសេរីភាព ជាមូលដ្ឋានរបស់សហជីព និងអង្គការសង្គមស៊ីវិល- ផ្សេងៗ គ្រឹះស្ថានសិក្សា និងប្រព័ន្ធផ្សព្វផ្សាយ ដោយហាមឃាត់មិនឲ្យមាន "ការជំទាស់" ចំពោះប្រាក់ឈ្នួលដែលបានកំណត់ និងហាមឃាត់មិនឲ្យមានការស្រាវជ្រាវដោយឯករាជ្យអំពីបញ្ហាប្រាក់ឈ្នួល។ សេចក្តីព្រាងច្បាប់សំខាន់ៗផ្សេងៗទៀត ដែលផលប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិមនុស្ស កំពុងត្រូវបានរៀបចំ តាមដំណាក់កាលផ្សេងៗគ្នា រាប់សេចក្តីព្រាងច្បាប់មួយចំនួនដែលត្រូវរៀបចំដោយសំងាត់ មានដូចជា សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋតាមប្រព័ន្ធអ៊ីនធឺណេត និងសេចក្តីព្រាងច្បាប់ស្តីពីការសម្ងាត់រដ្ឋ។ ការិយាល័យOHCHR បានចូលរួមយ៉ាងសកម្មក្នុងដំណើរការពិគ្រោះយោបល់ដោយចំហរ ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដែលក្រសួងព័ត៌មានបានដឹកនាំធ្វើតាំងពីឆ្នាំ២០១៤ ក្រោមជំនួយគាំទ្រពីអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ(UNESCO)។ ការិយាល័យOHCHR បានចូលរួមក្នុងក្រុមការងាររៀបចំសេចក្តីព្រាង ហើយបានចូលរួមចំណែកធ្វើការបណ្តុះបណ្តាលជាច្រើន និងរៀបចំវេទិកាសហគមន៍នៅទូទាំងប្រទេស ដើម្បីលើកស្ទួយការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការនេះ។

២២. ក្នុងខែតុលា ឆ្នាំ២០១៦ ការិយាល័យOHCHR បានចូលរួមក្នុងពិធីរំលឹកខួបលើកទី២៥ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលរៀបចំដោយរាជរដ្ឋាភិបាល ហើយបានគាំទ្រដល់ព្រឹត្តិការណ៍ផ្សេងៗរបស់សង្គមស៊ីវិលនៅថ្នាក់តំបន់និងថ្នាក់ជាតិ។ ការយកចិត្តទុកដាក់យ៉ាងច្រើននៃពិធីនេះ គឺផ្តោតទៅលើទស្សនៈនៃកិច្ចព្រមព្រៀងដែលថា ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន គឺជាមូលដ្ឋានជាសារវ័ន្ត ដើម្បីធានាឲ្យមានសន្តិ-ភាពយូរអង្វែង។ កាលពីខែមីនា ឆ្នាំ២០១៧ ការិយាល័យOHCHR សហការជាមួយគណៈ-កម្មាធិការសិទ្ធិមនុស្សកម្ពុជា បានរៀបចំសន្និសីទសាធារណៈថ្នាក់ជាតិមួយស្តីពី "សិទ្ធិមនុស្សនៅកម្ពុជាបច្ចុប្បន្ន" ដែលមានការចូលរួមពីស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយជាច្រើន។ ការិយាល័យOHCHR បានរៀបចំកិច្ចប្រជុំមួយជាមួយសកម្មជនសហគមន៍មូលដ្ឋាន និងសកម្មជនផ្សេងទៀតប្រមាណ ៣០ នាក់ ដែលមកពីទូទាំងប្រទេស និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD)។ អ្នកចូលរួមបានចែករំលែកដោយផ្ទាល់ជាមួយតំណាងមកពី NCDD អំពីបញ្ហាប្រឈមផ្សេងៗដែលពួកបានជួបប្រទះ បានស្នើសុំជំនួយពី NCDD និងបានយល់ដឹងអំពីដំណើរការវិមជ្ឈការ។

២៣. ការិយាល័យOHCHR បានបន្តជួយពង្រឹងសមត្ថភាពសិទ្ធិមនុស្សរបស់អង្គការសង្គមស៊ីវិលរបស់កម្ពុជា។ ការិយាល័យ បានរៀបចំការបណ្តុះបណ្តាលចំនួន៤ ស្តីពីវិធីសាស្ត្រឃ្លាំមើលសិទ្ធិមនុស្ស ស្វែងរកការពិត និងការធ្វើរបាយការណ៍ និងសន្តិសុខ និងកិច្ចការពារដល់សកម្មជនចំនួន ១៦៨ នាក់ (ក្នុងនោះមានស្ត្រីចំនួន ៥០ នាក់) ដែលមកពីខេត្ត-ក្រុងចំនួន ១៥។ អ្នកចូល

រួម បានវាយតម្លៃខ្ពស់អំពីភាពពាក់ព័ន្ធនៃការបណ្តុះបណ្តាលនេះ ទៅនឹងការងារប្រចាំថ្ងៃរបស់ពួកគេ ជាពិសេសអំពីសារៈសំខាន់ក្នុងការផ្ទៀងផ្ទាត់ វិភាគអង្គហេតុ ចងក្រងឯកសារជាលក្ខណៈប្រព័ន្ធ និងការយល់ដឹងអំពីបញ្ហាប្រឈមផ្សេងៗ។ ការិយាល័យ បានទទួលការអញ្ជើញពីដៃគូមួយចំនួន ឲ្យធ្វើបទបង្ហាញវគ្គជំនាញជាច្រើននៅក្នុងការបណ្តុះបណ្តាលដែលរៀបចំឡើង ដោយអង្គការទាំងនេះ មានដូចជា បទបង្ហាញអំពីសិទ្ធិមនុស្សជាមូលដ្ឋាន ការឃ្លាំមើល សុវត្ថិភាព ឬសិទ្ធិឯកជន ដែលមានសកម្មចំនួន ១១៨ នាក់ ក្នុងនោះមានស្ត្រីចំនួន ២៤ នាក់ បានចូលរួម។

២៤. ឆ្លើយតបនឹងសំណើរពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(NEC) ដើម្បីសុំជំនួយឧបត្ថម្ភក្នុងការលើកកម្ពស់ការយល់ដឹងអំពីដំណើរបោះឆ្នោត ជាពិសេស ក្នុងចំណោមយុវជន ការិយាល័យ បានគាំទ្រដល់វគ្គផ្សព្វផ្សាយខ្លីៗនៅតាមសកលវិទ្យាល័យ និងស្ថាប័នអប់រំជាច្រើន ដែលក្នុងវគ្គទាំងនោះ បានផ្តោតទៅលើសិទ្ធិបោះឆ្នោត និងសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ។ ក្រោយពីការស្នើសុំជំនួយឧបត្ថម្ភពី NEC ដល់កម្មវិធីអប់រំពលរដ្ឋរយៈពេលវែងរបស់ខ្លួន (ជាពិសេសសម្រាប់សិស្សវិទ្យាល័យ) ការិយាល័យOHCHR បានធ្វើការទំនាក់ទំនងជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដាក់បញ្ចូលខ្លឹមសារនេះ ទៅក្នុងកម្មវិធីផ្លូវការរបស់សាលារៀន។ ការិយាល័យ បានជួបប្រជុំជាច្រើនលើកជាមួយ NEC និងក្រសួង ព្រមទាំងស្ថាប័នបណ្តុះបណ្តាលជំនាញរយៈពេលខ្លី ដើម្បីពិនិត្យមើលការអប់រំអំពីសិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជានៅប្រទេសកម្ពុជា និង ដើម្បីផ្តល់យោបល់ និងអនុសាសន៍។

## III. ការលើកកំពស់នីតិរដ្ឋ

២៥. ការិយាល័យ OHCHR បន្តគាំទ្រដំណើរការកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីពង្រឹងនីតិរដ្ឋ និងធ្វើការយ៉ាងសកម្មជាមួយក្រសួងយុត្តិធម៌ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចៅក្រម និងព្រះរាជអាជ្ញាគ្រប់ជាន់ថ្នាក់ និងមេធាវីផង ក្នុងចំណោមអ្នកដទៃទៀត។ ការងារបានផ្តោះទៅមុខលើវិស័យមួយចំនួនដែលបានឯកភាពគ្នា ជាពិសេស ទាក់ទងនឹងការរៀបចំអង្គការតុលាការ ការដាក់ទោសជំនួស និងការធ្វើទំនាក់ទំនងក្នុងប្រព័ន្ធយុត្តិធម៌។ ថវិការដ្ឋាភិបាលសំរាប់វិស័យយុត្តិធម៌នៅឆ្នាំ២០១៧ បានបន្តកើនឡើង បើធៀបនឹងឆ្នាំមុនៗ ទោះបីជាថវិកានេះ នៅតែមានចំនួនទាបជាង ១% នៃថវិកាជាតិក៏ដោយ។

២៦. ការវិវត្តន៍មុនការបោះឆ្នោត បានបង្ហាញនូវកង្វះរចនាសម្ព័ន្ធមួយចំនួនក្នុងស្ថាប័នតុលាការ និងស្ថាប័នប្រតិបត្តិច្បាប់ ដែលត្រូវបានគូសបញ្ជាក់ជាយូរមកហើយដោយយន្តការសិទ្ធិមនុស្សអន្តរជាតិ រួមមាន កង្វះឯករាជភាព និងកិច្ចធានាការពារតាមនីតិវិធី មូលដ្ឋានភស្តុតាងមានលក្ខណៈទន់ខ្សោយសំរាប់ការផ្តន្ទាទោស និងករណីនិទណ្ឌភាពនៅតែបន្តមាន។ ការិយាល័យOHCHR បន្តកំណត់បញ្ហាប្រឈមទាំងនេះជាអាទិភាព ក្នុងការគាំទ្រខាងបច្ចេកទេសរបស់ខ្លួន ដល់កម្ម-វិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រដ្ឋាភិបាល។

២៧. នៅកម្រិតធ្វើគោលនយោបាយ ការិយាល័យOHCHR បានបន្តដើរតួនាទីជាអ្នកសម្របសម្រួលដៃគូអ្នកផ្តល់ជំនួយនៃក្រុមការងារបច្ចេកទេសស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ តាម រយៈនេះ រដ្ឋាភិបាល និងម្ចាស់ជំនួយ សម្របសម្រួលជំនួយអន្តរជាតិ និងផ្លាស់ប្តូរគ្នាអំពី

ទិសដៅគោលនយោបាយ។ ការិយាល័យOHCHR បានធ្វើការជាមួយក្រសួងយុត្តិធម៌ដែលដើរតួនាទីជាប្រធានក្រុមការងាររបស់រដ្ឋាភិបាល ក្នុងការវាយតំលៃពីការអនុវត្តតាមសូចនាករតាមដានរួមសំរាប់ឆ្នាំ២០១៤-២០១៦ និងជួយកំណត់សូចនាករតាមដានរួមថ្មីៗសំរាប់ឆ្នាំ២០១៧-២០១៨។ ជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បី "ធ្វើឱ្យ" គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព អនុវត្តនៅមូលដ្ឋាន ក្រុមការងារនេះ បានធ្វើសមាហរណកម្មគោលដៅ និងសូចនាករស្ទើរតែទាំងអស់ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៦ ស្តីពីប្រព័ន្ធយុត្តិធម៌ សន្តិភាព និងសិទ្ធិមនុស្ស ទៅក្នុងផែនការការងាររបស់ខ្លួន។

២៨. ក្របខ័ណ្ឌច្បាប់ត្រូវបានពង្រឹង តាមរយៈការអនុម័តច្បាប់ដែលរង់ចាំជាយូរមកហើយនោះ គឺច្បាប់ស្តីពីយុត្តិធម៌អនីតិជននៅឆ្នាំ២០១៦។ ច្បាប់នេះបង្កើតប្រព័ន្ធដោយឡែកមួយ ដែលផ្តោតលើកម្មវិធីបង្វែរ ជាជាងការដាក់ទោសពន្ធនាគារ។ ការិយាល័យOHCHR ជាមួយដៃគូផ្សេងៗ បានផ្តល់ជំនួយបច្ចេកទេសដល់ក្រុមការងារស្តីពីការអនុវត្តច្បាប់នេះ ទាក់ទងនឹងផែនការរយៈពេល ៣ ឆ្នាំរបស់ខ្លួន។ ការិយាល័យOHCHR បានឃ្លាំមើលដំណើរការព្រាងច្បាប់ស្តីពីការការពារសាក្សី និងបុគ្គលរាយការណ៍ ដែលដឹកនាំដោយអង្គភាពប្រឆាំងអំពើពុករលួយ ដោយធ្វើការទំនាក់ទំនងជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

២៩. ក្រសួងយុត្តិធម៌បានបន្តអនុវត្ត "ច្បាប់គោលទាំងបី" ស្តីពីស្ថាប័នតុលាការ ដោយដាក់ឱ្យប្រើនូវអនុក្រឹត្យចំនួន៣ ទាក់ទងនឹងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបោះជំហានទៅមុខទៀតសំដៅព្រាងច្បាប់ស្តីពីសារការី ច្បាប់ស្តីពីអាជ្ញាសាលា និងលក្ខន្តិកៈក្រឡាបញ្ជី។ ក្រសួងបានជ្រើសរើសបុគ្គលិកបន្ថែមសំរាប់អគ្គនាយកដ្ឋានរដ្ឋបាលតុលាការ និងលេខាធិការដ្ឋានរដ្ឋបាលតុលាការ។ ការិយាល័យOHCHR បានគាំទ្រនូវការកែលម្អការគ្រប់គ្រងសំណុំរឿង និងសិទ្ធិទទួលបានព័ត៌មានតុលាការរបស់អ្នកប្រើប្រាស់សេវាតុលាការ និងសាធារណៈជនទូទៅ តាមរយៈការពង្រីកបន្ថែមនូវប្រព័ន្ធទិន្នន័យចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌ នៅតាមសាលាដំបូងចំនួន ៥ ទៀតបន្ថែមទៅលើសាលាដំបូងចំនួន ៦ ដែលបានទទួលការតម្លើងប្រព័ន្ធនេះនៅឆ្នាំ២០១៥។ ការវាយតម្លៃរួមចំពោះការប្រើប្រាស់ប្រព័ន្ធទិន្នន័យនេះ នៅតាមតុលាការចំនួន ៣ ជាទូទៅបានរកឃើញលទ្ធផលជាវិជ្ជមានក្នុងការលើកកំពស់ប្រសិទ្ធភាព និងតម្លាភាពតុលាការ ទោះបីជាជួបឧបសគ្គខ្លះក្នុងការប្រើប្រាស់ និងការថែទាំក៏ដោយ។ កម្មវិធីថ្មីមួយចំនួនត្រូវបានដាក់បញ្ចូលបន្ថែម ដើម្បីតាមដានព័ត៌មានទាក់ទងនឹងជនពិការ អំពើហិង្សាប្រឆាំងនឹងនារីភេទ ព្រមទាំងអំពើជួញដូរគ្រឿងញៀន និងអំពើជួញដូរមនុស្ស។ ក្រោយពីបានតម្លើងប្រព័ន្ធទិន្នន័យនេះនៅតាមសាលាដំបូងបានចំនួនពាក់កណ្តាល នៅត្រឹមដំណាច់ឆ្នាំ២០១៧ ការិយាល័យ OHCHR នឹងបន្តគាំទ្រការតម្លើងប្រព័ន្ធទិន្នន័យបែបនេះ ឲ្យបានដល់សាលាដំបូងទាំងអស់។

៣០. នៅក្នុងខែសីហាកន្លងទៅ ការិយាល័យOHCHR និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានរៀបចំសិក្ខាសាលាចុងក្រោយនៃសិក្ខាសាលាជាស៊េរីមួយ ដើម្បីផ្សព្វផ្សាយក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០០៧ ហើយសិក្ខាសាលាជាស៊េរីនេះ បានចាប់ផ្តើមធ្វើឡើងតាំងពីដើមឆ្នាំ២០១៦ មកម្ល៉េះ ហើយចៅក្រម និងព្រះរាជអាជ្ញាចំនួនលើសពី ៩០% មកពីតុលាការជាន់ទាប និងតុលាការជាន់ខ្ពស់ទាំងអស់ ២៥ សាលា បានទទួលផលប្រយោជន៍ពី

សិក្ខាសាលាទាំងនេះ។ រួមគ្នាជាមួយវិទ្យាស្ថាន Raoul Wallenberg និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ការិយាល័យOHCHR បានផ្តល់ការបណ្តុះបណ្តាលដល់សិស្សចៅក្រម -ព្រះរាជអាជ្ញា និងសិស្សក្រឡាបញ្ជីចំនួនប្រហែល ១០០ នាក់ អំពីសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ផ្អែកលើសេចក្តីពន្យល់ក្រមនីតិវិធីព្រហ្មទណ្ឌបោះពុម្ពលើកទី២ ដែលត្រូវបានបោះផ្សាយកាលពីឆ្នាំ២០១៥។

៣១. រួមគ្នាជាមួយក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការិយាល័យOHCHR បានចុះបំពេញការងារតាមដានបន្តនៅតុលាការខេត្តចំនួនប្រាំ ដើម្បីវាយតម្លៃពីការប្រើប្រាស់រូបមន្តថ្មីនៃដីកាឃុំខ្លួនបណ្តោះអាសន្នដែលបានកែសម្រួលកាលឆ្នាំ២០១៤។ ត្រូវបានសង្កេតឃើញថាមានការកើនឡើងនូវការយល់ដឹង និងការប្រើប្រាស់រូបមន្តថ្មីក្នុងចំណោមចៅក្រម។ បើទោះបីជាមានការតវ៉ាពីចៅក្រមមួយចំនួនក្តី ទម្រង់ថ្មីនេះបានស្តែងចេញជាលទ្ធផល ក្នុងការដាក់បញ្ចូលពីសំអាងហេតុផ្នែកច្បាប់ត្រឹមត្រូវ និងរយៈពេលយ៉ាងច្បាស់នៃការឃុំខ្លួននៅក្នុងករណីមួយចំនួន។ ចំណុចស្នូលចំពោះគុណភាពនៃសំអាងហេតុផ្លូវច្បាប់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ គឺការវិភាគភស្តុតាង។ ក្រោមកម្មវិធីកែទម្រង់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) របស់ខ្លួន និងជាផ្នែកមួយនៃកិច្ចសន្ទនាផ្នែកច្បាប់ជាស៊េរី អនុវត្តរួមគ្នាជា មួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ការិយាល័យOHCHR បានអនុវត្តសកម្មភាពចំនួនពីរ ដើម្បីពង្រឹងដល់ការវិភាគភស្តុតាង ការលើកសំអាងហេតុផ្លូវច្បាប់សំរាប់ការឃុំខ្លួនបណ្តោះអាសន្ន បច្ចេកទេសសួរដេញដោល និងការប្រើប្រាស់បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនៅក្នុងតុលាការជាតិ។ ចំណុចនេះ ក៏ត្រូវបានយកមកពិនិត្យផងដែរ ក្នុងអំឡុងពេលកិច្ចប្រជុំធ្វើបច្ចុប្បន្នភាពកែទម្រង់ អ.វ.ត.ក ដែលរៀបចំឡើងដោយការិយាល័យOHCHR កាលពីខែកុម្ភៈ ឆ្នាំ២០១៧។

៣២. លិខិតុបករណ៍សំខាន់មួយទៀតដល់ការផ្តល់យុត្តិធម៌ គឺលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់។ ថវិកាជាតិសម្រាប់ជំនួយផ្នែកច្បាប់ចន្លោះឆ្នាំ២០១៣ និងឆ្នាំ២០១៧ កើនឡើងបីដង ប៉ុន្តែមានចំនួនតែ ១៥០.០០០ ដុល្លារ អាមេរិក ប៉ុណ្ណោះ ដែលនៅតែមិនគ្រប់គ្រាន់សម្រាប់ប្រទេសមួយដែល ប្រជាជនជិតពាក់កណ្តាលរស់នៅក្រោម ឬគ្រាន់តែលើបន្តិចនៃបន្ទាត់ភាពក្រីក្រ។ [12] ដោយសហការជាមួយក្រសួងយុត្តិធម៌ និងបណ្តាញអង្គការជំនួយផ្នែកច្បាប់តំបន់អាស៊ីអគ្នេយ៍ ការិយាល័យOHCHR បានរៀបចំសិក្ខាសាលាមួយស្តីពីការអនុវត្តល្អៗក្នុងតំបន់ ក្នុងការបង្កើតគោលនយោបាយជំនួយផ្នែកច្បាប់ដែលនឹងគ្រោងធ្វើនៅខែសីហា ឆ្នាំ២០១៧។ ដើម្បីជួយដោះស្រាយពីសេចក្តីត្រូវការភ្លាមៗ ការិយាល័យបានផ្តល់កញ្ចប់ជំនួយថ្មីមួយដល់ដៃគូអង្គការមិនមែនរដ្ឋាភិបាល(NGO) ដើម្បីជួយកំណត់អំពីប្រភេទនៃអ្នកទោស រហូតដល់សាលក្រម ឬសាលដីកាស្ថាពរអាចត្រូវបានអនុវត្ត [13] និងជួយជម្រះការកកស្ទះបណ្តឹងឧទ្ធរណ៍។ ក្នុងចំណោមបណ្តឹងឧទ្ធរណ៍ជាអាទិភាពចំនួន១៩១ ករណី បានរកឃើញក្នុងពន្ធនាគារចំនួនប្រាំ ហើយ

[12] សូមមើលកថាខណ្ឌទី៣

[13] បុគ្គលណាម្នាក់អាចនឹងត្រូវបានដោះលែងក្រោយពីទទួលបានសាលក្រមស្ថាពរ។ ដោយឡែក អ្នកដែលត្រូវបានលើកលែងចោទប្រកាន់ ប៉ុន្តែនៅជាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងពួកគេ គឺនៅតែជាប់ឃុំជាដដែល។

រហូតមកដល់ពេលនេះ មានតែសាលក្រមចំនួន ១០ ប៉ុណ្ណោះ ដែលទទួលបាន និងចែករំលែក ជាមួយអ្នកទោស ១៤ ករណីត្រូវបានបិទ ក្នុងនោះមួយករណីត្រូវបានដោះលែង និង ១១ ករណីទៀត ត្រូវបានកំណត់កាលបរិច្ឆេទជំនុំជម្រះ។

៣៣. ករណីខាងលើនេះ ត្រូវបានយកមកពិភាក្សាជាថ្មីម្តងទៀត អំពីតម្រូវការកែលម្អទំនាក់ទំនងនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ នៅថ្នាក់មូលដ្ឋាន ការិយាល័យOHCHR បានបន្តគាំទ្រដល់កិច្ចប្រជុំជាទៀងទាត់រវាងមន្ត្រីនគរបាល តុលាការ និងពន្ធនាគារ។ ចន្លោះពីខែកញ្ញា ឆ្នាំ២០១៦ និងខែឧសភា ឆ្នាំ២០១៧ ការិយាល័យបានគាំទ្រកិច្ចប្រជុំចំនួនបួននៅក្នុងខេត្តចំនួនបី ដែលមន្ត្រីសំខាន់ៗទាំងនេះ បានពិភាក្សាអំពីបញ្ហាប្រឈមដែលបានជួបប្រទះក្នុងការងារប្រចាំថ្ងៃរបស់ពួកគេ ចំណុចណាដែលត្រូវមានកិច្ចសហការកាន់តែខ្លាំង និងដំណោះស្រាយដែលអាចធ្វើបាន ដើម្បីកែលម្អការផ្តល់សេវាយុត្តិធម៌នៅកម្រិតរបស់ពួកគេ។

៣៤. ចំពោះនៅថ្នាក់ក្រោមជាតិដែរ ការិយាល័យOHCHR បានបន្តការបណ្តុះបណ្តាល ធ្វើនៅក្នុងឆ្នាំ២០១៥ សម្រាប់មន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថខេត្ត អំពីការបង្ការទារុណកម្ម និងការប្រព្រឹត្តមិនគប្បី និងការប្រើកម្លាំងដោយមន្ត្រីអនុវត្តច្បាប់។ ក្នុងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយការិយាល័យព្រះរាជអាជ្ញាខេត្ត បានបន្តបណ្តុះបណ្តាលអំពីសិទ្ធិមនុស្សដល់មន្ត្រីអនុវត្តច្បាប់នៅថ្នាក់ស្រុក បានចំនួន ៤៦០ នាក់ ក្នុងខេត្តព្រៃវែង។ ពួកគេបានបង្ហាញពីឱកាសដ៏កម្រមួយសម្រាប់មន្ត្រីស្រុក ផ្លាស់ប្តូរយោបល់ដោយផ្ទាល់ជាមួយមន្ត្រីព្រះរាជអាជ្ញា នៅក្នុងតួនាទីត្រួតពិនិត្យរបស់ខ្លួនលើមន្ត្រីនគរបាលយុត្តិធម៌។

៣៥. និទណ្ឌភាពនៅតែជាឧបសគ្គដល់ការគោរពសិទ្ធិមនុស្សឲ្យបានពេញលេញ នៅប្រទេសកម្ពុជា ដែលនាំឱ្យមានការមិនទុកចិត្តជាយូរមកហើយនៅក្នុងប្រព័ន្ធយុត្តិធម៌ និងបង្កើតជាលក្ខខណ្ឌនានា សម្រាប់ការដោះស្រាយទន្ទឹមគ្នា ដូចជាការទូទាត់ហិរញ្ញវត្ថុក្រៅតុលាការនៅក្នុងករណីព្រហ្មទណ្ឌ ឬសកម្មភាពអប្បមាទ។ ការិយាល័យOHCHR បានបន្តឃ្លាំមើលករណីបុគ្គលដោយប្រាស្រ័យទាក់ទងជាមួយនឹងក្រុមគ្រួសាររបស់ជនរងគ្រោះ និងអាជ្ញាធរមូលដ្ឋាន។ ការិយាល័យបានសង្កេតឃើញអំពីរបៀបដែលក្រុមគ្រួសារនៃជនរងគ្រោះ នៅក្នុងស្ថានភាពនៃភាពងាយរងគ្រោះអាចមានអារម្មណ៍ថាលទ្ធផលប្រសើរបំផុតគឺសំណងហិរញ្ញវត្ថុ ដោយជំនួសមកវិញសម្រាប់កិច្ចព្រមព្រៀងទាំងមិនដាក់ ឬដកពាក្យបណ្តឹងជាផ្លូវការ។ បើទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ មិនតម្រូវឱ្យមានពាក្យ បណ្តឹងសម្រាប់បើកការស៊ើបសួរព្រហ្មទណ្ឌក្តី នៅពេលដែលពាក្យបណ្តឹងមួយត្រូវបានទំលាក់ចោល ជាធម្មតារឿងក្តីនោះត្រូវបញ្ចប់ត្រឹមហ្នឹងតែម្តង សូម្បីតែនៅក្នុងរឿងក្តីព្រហ្មទណ្ឌធ្ងន់ធ្ងរក៏ដោយ។ ការិយាល័យOHCHR បានបន្តការតស៊ូមតិជាមួយអាជ្ញាធរតុលាការថា ករណីទាំងអស់គួរតែត្រូវបានស៊ើបអង្កេតឱ្យបានគ្រប់គ្រាន់ ហើយជនដៃដល់ត្រូវតែបាននាំខ្លួនទៅតុលាការ។

៣៦. ការិយាល័យOHCHR បានឃ្លាំមើលស៊េរីនៃករណី "យុត្តិធម៌ដោយហ្វូងមហាជន" ដែលពាក់ព័ន្ធនឹងភាពខុសគ្នានៃបទល្មើសដែលបានចោទប្រកាន់ - ចាប់ពីចោរកម្មតូចតាច ករណីប្លន់ ការរំលោភសេពសន្ថវៈ ឬឃាតកម្ម - និងការចោទប្រកាន់ពីអំពើអាបធ្មប់។ ក្នុងករណីជាច្រើន នគរបាល និងអាជ្ញាធរមូលដ្ឋានបានប្រានចោលសកម្មភាពបែបនេះរបស់ហ្វូងមហាជន ដោយ

លើកថាជា "ការបង្ហាញកំហឹង" ឬ "អំពើនៃការសងសឹក" ដែលនាំឲ្យមានការស៊ើបអង្កេតតិចតួច និងមានការទទួលខុសត្រូវតិចតួចរបស់បុគ្គលដែលពាក់ព័ន្ធ។ ជារឿយៗ នគរបាលនឹងធ្វើការស៊ើបអង្កេតសកម្មភាពដែលនាំឱ្យមានប្រតិកម្មរបស់ក្រុមមហាជន (ឧទាហរណ៍ ចោរកម្ម) ប៉ុន្តែមិនស៊ើបអង្កេតអំពើមនុស្សឃាតទេ ដោយត្រូវបានចាត់ទុកនាពេលនោះថាបានផ្តល់យុត្តិកម្មរួចហើយ។ ក្នុងករណីខ្លះ នគរបាលដឹងថា ពួកគេមិនអាចធ្វើអន្តរាគមន៍ដោយសុវត្ថិភាពបាន ដោយសារអ្នកភូមិមានចំនួនច្រើនលើសលប់។ ការិយាល័យOHCHR បានទទួលសំណើពីនគរបាលមូលដ្ឋាន នៅតាមឃុំនិងស្រុក ឱ្យលើកកម្ពស់ ការយល់ដឹងរបស់អ្នកភូមិអំពីសិទ្ធិមនុស្ស និងដំណើរការត្រឹមត្រូវ ដើម្បីជួយបង្ការការសម្លាប់ដោយហ្វូងមនុស្ស។

៣៧. ការិយាល័យOHCHR បានបន្តឃ្លាំមើលយ៉ាងជិតស្និទ្ធអំពីដំណើរការងាររបស់ អ.វ.ត.ក ដោយធ្វើការពិចារណាអំពីទំលាប់អនុវត្តន៍ល្អៗរបស់តុលាការ ក្នុងការលើកកម្ពស់ប្រព័ន្ធតុលាការជាតិ។ ការិយាល័យOHCHR បានបន្តរៀបចំកិច្ចប្រជុំស្តីពីកេរ្តិ៍ដំណែល អ.វ.ត.ក ក្នុងចំណោមដៃគូការងារពាក់ព័ន្ធទាំងអស់ ព្រមទាំងបានឆ្លុះបញ្ចាំងសំណើមួយចំនួន ដែលទទួលបានពីពួកគេនៅក្នុងការអនុវត្តការងាររួមគ្នារបស់ខ្លួនជាមួយក្រសួងយុត្តិធម៌ដូចបានគូសបញ្ជាក់ខាងលើ។

## IV. ការគាំទ្រកំណែទម្រង់ពន្ធនាគារ

៣៨. កិច្ចសហការយ៉ាងជិតស្និទ្ធនៅតែបន្តមានរវាងអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ និងស្ថាប័នបណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីគាំទ្រកំណែទម្រង់ និងការគ្រប់គ្រងពន្ធនាគារដោយផ្អែកលើសិទ្ធិមនុស្ស។ នៅក្នុងអំឡុងពេលនៃឆ្នាំធ្វើរបាយការណ៍នេះ ទាំងក្រសួងបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកដ្ឋានពន្ធនាគារ ហើយនិងពន្ធនាគារទាំងឡាយ បាន និងកំពុងស្ថិតនៅក្នុងស្ថានភាពកែសម្រួលនិងផ្លាស់ប្តូរថ្នាក់ដឹកនាំ។ យន្តការបច្ចុប្បន្នដែលត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តឬការដាក់ទណ្ឌកម្មដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ក៏កំពុងស្ថិតនៅក្នុងដំណាក់កាលពិនិត្យឡើងវិញ និងកែសម្រួលតាមរយៈសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ដែលនឹងត្រូវនិរាករណ៍អនុក្រឹត្យបច្ចុប្បន្ននៅពេលព្រះរាជក្រឹត្យនេះចូលជាធរមាន។ យន្តការដែលមាននាពេលបច្ចុប្បន្ននេះមិនអាចផ្តល់ការឃ្លាំមើលដែលមានលក្ខណៈឯករាជ្យឡើយ ហើយដែលការណ៍នេះបានគូសបញ្ជាក់អំពីការខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងពិធីសារខាងលើ។

៣៩. វាជាការគួរឱ្យសោកស្តាយដែលសេចក្តីអនុញ្ញាតដែលចេញដោយអគ្គនាយកដ្ឋានពន្ធនាគារឱ្យការិយាល័យOHCHR ធ្វើទស្សនកិច្ចពន្ធនាគារ នៅតែរក្សាទុកខ្លឹមសារស្តីពីការមិនអនុញ្ញាតឱ្យធ្វើសម្ភាសន៍សម្ងាត់ ដែលការកំហិតនេះចាប់ផ្តើមមានឡើងចាប់តាំងពីឆ្នាំ២០១៦ មក ហើយសម្រាប់ឆ្នាំ២០១៧ នេះ ការអនុញ្ញាតត្រូវបានផ្តល់ជូនសម្រាប់តែរយៈពេលកន្លះឆ្នាំម្តង។ កាលពីអតីតកាលរហូតដល់ ខែធ្នូ ឆ្នាំ២០១៥ សេចក្តីអនុញ្ញាតដែលចេញដោយអគ្គនាយកដ្ឋានពន្ធនាគារគឺធ្វើឡើងសម្រាប់រយៈពេលមួយឆ្នាំម្តង ហើយតែងតែបញ្ចូលការអនុញ្ញាតឱ្យមានការ

សម្ភាសន៍សម្ងាត់។ ការទទួលបានយ៉ាងពេញលេញនូវការជួបប្រាស្រ័យទាក់ទងជាសម្ងាត់រវាងការិយាល័យOHCHR ជាមួយជនជាប់ឃុំគឺមានលក្ខណៈសំខាន់ទាំងទៅលើការធានាបាននូវគុណភាពនិងសុវត្ថិភាពនៃការប្រាស្រ័យទាក់ទងជាមួយជនជាប់ឃុំ ទាំងការធានាដល់ការកសាង ការអនុវត្ត និងការឃ្លាំមើលលទ្ធផលនៃការអនុវត្តយុទ្ធសាស្រ្តនៃការងារគាំទ្រអាជ្ញាធរពន្ធនាគារ។ មិនតែប៉ុណ្ណោះ ការទទួលបានសិទ្ធិប្រាស្រ័យទាក់ទងជាមួយអ្នកការពារសិទ្ធិមនុស្សទាំងប្រាំរូបដ៏ល្បីឈ្មោះ (ដូចមានរៀបរាប់ខាងលើ) ក៏ត្រូវបានរឹតត្បិតថែមមួយកម្រិតទៀតដោយអាជ្ញាធរតុលាការ។

៤០. កម្មវិធីគាំទ្រពន្ធនាគាររបស់ការិយាល័យOHCHR ផ្តោតជាមូលដ្ឋានទៅលើផ្នែកធំៗចំនួនពីរគឺការឃ្លាំមើល និងការគាំទ្រ ការតាមដានបន្តទៅលើវិធានការដោះស្រាយកែលម្អ ហើយនិងការកសាងសមត្ថភាពមន្ត្រីពន្ធនាគារឆ្ពោះទៅកាន់អភិក្រមមួយដែលធានាថាការគ្រប់គ្រងពន្ធនាគារត្រូវបានចាត់ចែងឡើងដោយផ្អែកលើសិទ្ធិមនុស្ស។ ការិយាល័យOHCHR បានធ្វើទស្សនកិច្ចចំនួន ៣២ លើក ទៅកាន់ពន្ធនាគារចំនួន ១៣ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ បន្ទាប់ពីការធ្វើទស្សនកិច្ចនីមួយៗ ការិយាល័យOHCHR បានលើកឡើងជាអនុសាសន៍ដាក់ជូនទៅថ្នាក់ដឹកនាំពន្ធនាគារសាមី ហើយបញ្ហារួមដែលពាក់ព័ន្ធនឹងពន្ធនាគារច្រើនចូលគ្នាក៏ត្រូវបានបញ្ជូនបន្តទៅអាជ្ញាធរថ្នាក់លើដើម្បីសម្រេចស្វែងរកដំណោះស្រាយ។

៤១. ក្នុងគោលដៅកែលម្អលក្ខខណ្ឌឃុំខ្លួន និងការប្រព្រឹត្តទៅលើជនជាប់ឃុំ ការិយាល័យOHCHR បានចូលរួមប្រជុំ និងសម្របសម្រួលជាមួយតួអង្គដទៃទៀត ដែលធ្វើការក្នុងវិស័យពន្ធនាគារ ហើយការិយាល័យOHCHR ក៏កំពុងរៀបចំជាសៀវភៅចងក្រងការផ្តល់សេវាផ្សេងៗទាក់ទងនឹងពន្ធនាគារនិងជនជាប់ឃុំ។ ការិយាល័យOHCHR ក៏បានបោះពុម្ពនិងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវប័ណ្ណប្រកាសរូបភាពស្តីពីសិទ្ធិរបស់ជនជាប់ឃុំ ហើយនិងការសួរសុខទុក្ខជនជាប់ឃុំនៅក្នុងពន្ធនាគារ ដែលត្រូវបានរួមគ្នាផលិតដោយអគ្គនាយកដ្ឋានពន្ធនាគារ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាដៃគូ។ ទន្ទឹមនឹងនេះដែរ ការិយាល័យOHCHR ក៏កំពុងឆ្លើយតបជាវិជ្ជមានចំពោះសំណើរបស់អាជ្ញាធរពន្ធនាគារក្នុងការផលិតខ្លឹមសារប័ណ្ណប្រកាសខាងលើក្នុងរូបភាពជាខិតប័ណ្ណខ្នាតតូច ដើម្បីទុកចែកដល់ជនជាប់ឃុំនៅពេលពួកគេត្រូវបានបញ្ជូនចូលក្នុងពន្ធនាគារ។ ក្នុងគោលបំណងសម្រួលឱ្យជនជាប់ឃុំដែលឈឺអាចទទួលការព្យាបាលនៅតាមមន្ទីរពេទ្យដោយមិនចាំបាច់ប្រើប្រាស់ឧបករណ៍បង្ខាំងបន្ថែម ការិយាល័យOHCHR បានសហការជាមួយអាជ្ញាធរសុខាភិបាលថ្នាក់ជាតិ មន្ទីរពេទ្យខេត្ត និងអាជ្ញាធរពន្ធនាគារ ក្នុងការសាងសង់បន្ទប់សុវត្ថិភាពចំនួនពីរ និងកន្លែងសម្រាប់មន្ត្រីអនុរក្សពន្ធនាគារយាម នៅមន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន ហើយការិយាល័យOHCHR ក៏កំពុងពិនិត្យលទ្ធភាពក្នុងការសាងសង់បន្ទប់សុវត្ថិភាពស្រដៀងគ្នានេះ នៅតាមខេត្តចំនួនពីរទៀត។

៤២. ក្រោមកិច្ចសហការជាមួយគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម ហើយនិង ការិយា-ល័យអង្គការសហប្រជាជាតិសម្រាប់សេវាផ្តល់គម្រោង(UNOPS) ការិយាល័យOHCHR ក៏បានពិភាក្សា និងតស៊ូមតិដល់ការព្រាងបញ្ចប់លិខិតបទដ្ឋានគតិយុត្តិដែលមានចែងក្នុងច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១ ពាក់ព័ន្ធនឹងបទដ្ឋានអប្បបរមាស្តីពីការកសាងនិងជួសជុលពន្ធនាគារ

ដែលត្រូវបានរង់ចាំជាយូរមកហើយ។ ការិយាល័យOHCHR បានជួបពិភាក្សាជាមួយ អគ្គនាយកដ្ឋានពន្ធនាគារ និងបានចែករំលែកនូវអនុសាសន៍លើសេចក្តីព្រាងបឋម បន្ថែមលើអត្ថបទស្តីពីសៀវភៅណែនាំផ្នែកបច្ចេកទេសសម្រាប់ការធ្វើផែនការពន្ធនាគារដែលផលិតដោយ UNOPS ។ សំណើសុំការគាំទ្រផ្នែកសម្ភារៈនៅក្នុងអំឡុងពេលនៃឆ្នាំធ្វើរបាយការណ៍នេះបន្តបញ្ជាក់ឱ្យឃើញអំពីតម្រូវការស្តីពីការរៀបចំផែនការកសាងពន្ធនាគារឱ្យបានកាន់តែប្រសើរចាប់តាំងពីដំណាក់កាលដំបូង និងបញ្ជាក់អំពីតម្រូវការលៃបម្រុងនិងបង្កើនថវិកាលើវិស័យនេះ។ យុទ្ធនាការប្រឆាំងគ្រឿងញៀនរយៈពេលប្រាំមួយខែ ដែលចាប់ផ្តើមតាំងពីខែមករា ឆ្នាំ ២០១៧ បានបណ្តាលឱ្យមានការកើនឡើងយ៉ាងគំហុកនៃចំនួនជនជាប់ឃុំ [14] នៅក្នុងប្រព័ន្ធពន្ធនាគារដែលកំពុងដាក់មនុស្សលើសពីសមត្ថភាពផ្ទុករបស់ខ្លួន ហើយដែលកំពុងផ្តល់ផលលំបាកដល់គ្រប់ហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារទាំងអស់ និងកំពុងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់លក្ខខណ្ឌរស់នៅ និងសុខភាពផ្លូវចិត្តរបស់ជនជាប់ឃុំ ព្រមទាំងប៉ះពាល់ដល់បរិស្ថានធ្វើការងាររបស់មន្ត្រីពន្ធនាគារផងដែរ។

៤៣. ទំនាក់ទំនង និងកិច្ចសម្របសម្រួលរវាងពន្ធនាគារនិងតួអង្គផ្សេងៗទៀតនៅក្នុងប្រព័ន្ធយុត្តិធម៌គឺជាកិច្ចការសំខាន់នៅក្នុងទិសដៅការពារសិទ្ធិរបស់ជនជាប់ឃុំ។ គិតត្រឹមពាក់កណ្តាលខែមេសា ឆ្នាំ២០១៧ មានជនជាប់ឃុំចំនួនតែ ២៦ ភាគរយ ប៉ុណ្ណោះ ដែលមានសាលក្រមឬសាលដីកាស្ថាពរ។ តាមរយៈការផ្តល់មូលនិធិស្តីពីជំនួយផ្នែកច្បាប់ដល់ជនជាប់ឃុំដែលមានសំណុំរឿងនៅជាប់ក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍ (សូមមើលកថាខណ្ឌទី ៣១) និងការចាត់ថ្នាក់ករណីអាទិភាព ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីទទួលបន្ទុកសំណុំរឿង ការិយាល័យ OHCHR បានជួយអន្តរាគមន៍ស្នើសុំឱ្យមានការធានាការដោះលែងជនជាប់ឃុំចំនួនប្រាំនាក់ដែលត្រូវបានឃុំខ្លួនលើសរយៈពេលកំណត់។ កិច្ចដំណើរការកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យសំណុំរឿងជនជាប់ឃុំ ដែលត្រូវបានចាប់ផ្តើមដំណើរការក្នុងឆ្នាំ២០១៥ (ហើយដែលមានគោលដៅតាមដាននិងកំណត់រយៈពេលជាក់លាក់នៃគ្រប់នីតិវិធីដែលពាក់ព័ន្ធនឹងជនជាប់ឃុំ) ត្រូវបានពន្យារពេលដោយសារបញ្ហាបច្ចេកទេស។

៤៤. ការិយាល័យOHCHR កំពុងបន្តកិច្ចសហការជាមួយគ្រូបង្គោលរបស់អគ្គនាយកដ្ឋានពន្ធនាគារ និង គ្រូបង្គោលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមន្ត្រីពន្ធនាគារ នៃបណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងគោលបំណងកែលម្អការបណ្តុះបណ្តាលមន្ត្រីពន្ធនាគារ។ ឆ្លើយតបទៅនឹងគោលបំណងនេះ ការិយាល័យOHCHR បានចូលរួមរៀបចំដំណើរទស្សនកិច្ចចំនួនបួនលើកសម្រាប់សិក្ខាកាមពន្ធនាគារចំនួន ១៤០ នាក់ និង គ្រូផ្នែកពន្ធនាគារចំនួន ២០ នាក់ ទៅកាន់ពន្ធនាគារចំនួនប្រាំមួយ។ ដំណើរទស្សនកិច្ចទាំងនេះអនុញ្ញាតឱ្យសិក្ខាកាមទាំងនោះអាចផ្សារភ្ជាប់ការរៀនសូត្ររបស់ខ្លួនទៅនឹងមជ្ឈដ្ឋានធ្វើការនៅក្នុងពន្ធនាគារជាក់ស្តែង។ នៅក្នុងខែកុម្ភៈ និង ខែមិថុនា ឆ្នាំ២០១៧ ការិយាល័យOHCHR បានធ្វើបទបង្ហាញស្តីពីការទប់ស្កាត់អំពើទារុណកម្ម និងវិធីសាស្រ្តគ្រប់គ្រងពន្ធនាគារផ្អែកលើសិទ្ធិមនុស្ស ដល់សិក្ខាកាមពន្ធនាគារចំនួន

---

[14] ចាប់ពីខែមករាដល់ខែមេសា ឆ្នាំ២០១៧ ជនជាប់ឃុំបានកើនឡើងត្រឹម ៣.២០៦ នាក់ ពោលគឺកើនឡើងបីដងធៀបនឹងរយៈពេលចាប់ពីខែមករាដល់ខែមេសា ឆ្នាំ២០១៦។

៨៩ នាក់ ដែលទើបនឹងត្រូវបានជ្រើសរើសថ្មី (ក្នុងចំណោមនោះមានសិក្ខាកាមខ្លះជាមន្ត្រីពន្ធនាគារដែលមិនទាន់ទទួលបានការបណ្តុះបណ្តាលនៅឡើយ)។ ការិយាល័យOHCHR ក៏បានចូលរួមរៀបចំកិច្ចប្រជុំពិភាក្សាចំនួនពីរថ្ងៃកាលពីខែកញ្ញា ឆ្នាំ២០១៦ ដើម្បីពិនិត្យឡើងវិញលើសេចក្តីព្រាងសៀវភៅបណ្តុះបណ្តាលគោលសម្រាប់គ្រូបង្រៀនផ្នែកពន្ធនាគារ ។ នៅក្នុងខែឧសភា ឆ្នាំ២០១៧ គ្រូបង្រៀនផ្នែកពន្ធនាគាររបស់បណ្ឌិត្យសភានគរបាលកម្ពុជាបានបញ្ចប់ការកែសម្រួលលើមេរៀនរបស់ខ្លួន ហើយបបញ្ជូនទៅកាន់ក្រុមប្រឹក្សាគ្រូដើម្បីពិនិត្យ និងសម្រេច។ មេរៀនដែលត្រូវបានកែសម្រួលហើយទាំងនោះនៅមិនទាន់បានចែករំលែកដល់ការិយាល័យOHCHR នៅឡើយទេ។ ហេតុដូចនេះ ការិយាល័យOHCHR នៅមិនទាន់អាចវាយតម្លៃបានថាខ្លឹមសារមេរៀនទាក់ទងនឹងសិទ្ធិមនុស្សត្រូវបានកែលម្អហើយ ឬនៅនោះដែរ។

## V. ការការពារសិទ្ធិសេដ្ឋកិច្ច និងសង្គម

៤៥. ការិយាល័យOHCHR ធ្វើការ ដើម្បីជួយការពារនិងលើកកម្ពស់សិទ្ធិមានលំនៅឋានសមរម្យនិងកម្រិតជីវភាពរស់នៅសមរម្យ ទប់ស្កាត់ការបណ្តេញចេញនិងការផ្លាស់ប្តូរទីលំនៅដោយបង្ខំ និងលើកកម្ពស់សុវត្ថិភាពនៃការកាន់កាប់ ព្រមទាំងធ្វើឲ្យមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀតអំពីតួនាទីធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស ដោយរួមមានទាំងការពារនិងលើកកម្ពស់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច។

៤៦. កាលពីខែមិថុនា ឆ្នាំ២០១៦ នៅពេលដែលភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់ (Gesellschaft für Internationale Zusammenarbeit, GIZ) បានលាឈប់ពីតួនាទីជាអ្នកសម្របសម្រួលផ្នែកដៃគូអភិវឌ្ឍន៍នៃក្រុមការងារបច្ចេកទេសដីធ្លី ដៃគូអភិវឌ្ឍន៍បានស្នើការិយាល័យOHCHR ឲ្យទទួលយកតួនាទីជាអ្នកសម្របសម្រួលនេះ ដែលសេចក្តីស្នើនេះត្រូវមានការយល់ព្រមពីប្រធានក្រុមការងារបច្ចេកទេសដីធ្លីរបស់រដ្ឋាភិបាល នោះគឺក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ នៅក្នុងឆ្នាំ២០១៧ ក្រសួងបានសម្រេចមិនបន្តក្រុមការងារបច្ចេកទេសនេះទៀតទេ ទន្ទឹមនេះ អតីតសមាជិកនៃក្រុមការងារនេះ ដែលមានទាំងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលបានបង្កើតក្រុមសម្របសម្រួលផ្នែកដីធ្លីមួយ។ តាមរយៈវេទិការនេះ និងវេទិការដទៃទៀត ការិយាល័យOHCHR បន្តសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលដែលសកម្មលើផ្នែកសិទ្ធិដីធ្លី និងផ្តល់ការគាំទ្រដល់រដ្ឋាភិបាលបំពេញកាតព្វកិច្ចសិទ្ធិមនុស្សជាតិនិងអន្តរជាតិរបស់កម្ពុជា។

៤៧. រដ្ឋាភិបាលបានធ្វើឲ្យមានការវិវឌ្ឍន៍យ៉ាងឆាប់រហ័ស ក្នុងកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ខ្លួន។ គិតត្រឹមខែមករា ឆ្នាំ២០១៧[15] មានការចេញ ឬផ្តល់ប័ណ្ណកម្មសិទ្ធិប្រហែលជា ៤,៤៥ លានក្បាលដី១៦ ស្មើនឹង ៦៣,៦% នៃក្បាលដីប៉ាន់ស្មានសរុបប្រមាណជា ៧ លានក្បាលដីនៅប្រទេសកម្ពុជា ដែលជារួមវាដំណើរការទៅតាមផែនការរបស់រដ្ឋាភិបាលដែលនឹងត្រូវសម្រេចឲ្យបាននូវការផ្តល់ប័ណ្ណកម្មសិទ្ធិដីចំនួន ៧០ ភាគរយ នៅចុងឆ្នាំ២០១៨។ ក្រសួងរៀបចំដែនដី បានបង្កើតយន្តការនិងនីតិវិធីពិសេសបណ្តោះអាសន្នមួយចំនួន ដើម្បីដោះស្រាយ

[15] របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខែមករា ឆ្នាំ២០១៧។

វិវាទដីធ្លីលេចធ្លោ ប៉ុន្តែ ស្ថិតិនៃចំនួនវិវាទដីធ្លីដែលសកម្មនៅតែមានភាពមិនច្បាស់លាស់ ដែលបង្កើតឲ្យមាននូវបញ្ហាប្រឈមចំពោះកិច្ចខំប្រឹងប្រែងជាបន្តរបស់រដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល ដើម្បីឈានដល់ការបិទសំណុំរឿងដីធ្លីរបស់សហគមន៍ពាក់ព័ន្ធ។ ក្នុងចំណោមយន្តការផ្សេងៗ ក្រសួងបានបង្កើតក្រុមការងារបច្ចេកទេសចំនួន ៣៦ ក្រុម ដើម្បីដោះស្រាយវិវាទដីធ្លីនៅទូទាំងប្រទេស។ ការិយាល័យOHCHR បានស្នើផ្តល់ការឧបត្ថម្ភគាំទ្រដល់ក្រុមការងារដែលដោះស្រាយវិវាទដីធ្លីដែលជាករណីតាមដានឃ្លាំមើលដោយការិយាល័យOHCHR ប៉ុន្តែពុំមានការឆ្លើយតបឡើយ។ នៅក្នុងឆ្នាំនេះ ការិយាល័យOHCHR បានតាមដានវិវាទដីធ្លីចំនួន ៦៧ ករណី ដែលមិនទាន់ដោះស្រាយ ដែលជម្លោះដីធ្លីទាំងនោះមានទាំងនៅទីក្រុងនិងជនបទ ហើយក៏មានជម្លោះដីធ្លីថ្មីចំនួន ៣ ករណី ផងដែរ ក្នុងនោះមាន២២ករណីពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីដទៃទៀត ដែលផ្តល់ដោយរដ្ឋាភិបាល ខណៈដែល ៤៥ ករណី ទៀតពាក់ព័ន្ធទៅនឹងការផ្ទេរដី។ ការិយាល័យOHCHR បានតាមដានករណីទាំងនេះតាមរយៈការចុះទស្សនកិច្ចតាមមូលដ្ឋាន ការសម្របសម្រួលកិច្ចពិភាក្សារវាងគូភាគីជម្លោះ ការឃ្លាំមើលសវនាការនៅតុលាការ និងការផ្តល់យោបល់ផ្នែកច្បាប់ទៅដល់សហគមន៍ និងអង្គការសង្គមស៊ីវិល។ មានករណីចំនួន៣ ដែលត្រូវបានពិចារណាបិទបញ្ចប់នៅខែឧសភា ឆ្នាំ២០១៧។

៤៨. កាលពីដើមឆ្នាំ២០១០ ការិយាល័យOHCHR បានធ្វើការសិក្សាវាយតម្លៃលើតំបន់ តាំងទីលំនៅថ្មីមួយចំនួននៅក្នុងទីក្រុងនិងជនបទ ហើយក៏នាំទៅដល់ការចេញផ្សាយនៅក្នុងឆ្នាំ ២០១២ នូវរបាយការណ៍នៃការសិក្សាស្តីពី "ការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅក្នុងប្រទេសកម្ពុជា- តម្លៃនៃផលប៉ះពាល់អវិជ្ជមានចំពោះមនុស្ស ឥទ្ធិពល និងដំណោះស្រាយ"។[16] ដើម្បីវាយតម្លៃពីការផ្លាស់ប្តូរចាប់តាំងពីពេលនោះមក ដោយផ្អែកទៅលើក្របខ័ណ្ឌសិទ្ធិមនុស្សជាតិនិងអន្តរជាតិ និងអនុសាសន៍ជាច្រើនរបស់យន្តការសិទ្ធិមនុស្សអន្តរជាតិ នៅក្នុងឆ្នាំ ២០១៧ ការិយាល័យOHCHR បានចាប់ផ្តើមសិក្សាវាយតម្លៃធ្វើបច្ចុប្បន្នភាពលើរបាយការណ៍សិក្សានាពេលកន្លងមក។ ការិយាល័យOHCHR បានប្រាស្រ័យទាក់ទងជាមួយក្រសួងរៀបចំដែនដី ដើម្បីផ្តល់ឲ្យមានកិច្ចសហការជិតស្និទ្ធជាមួយមន្ត្រីពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវនេះ និងបានស្នើសុំជាពិសេសនូវបញ្ជីផ្លូវការនៃការតាំងទីលំនៅថ្មី ដោយសារតែព័ត៌មានដែលមានជាសាធារណៈអំពីបញ្ហានេះមានភាពខ្វះចន្លោះ ហើយមានភាពខុសគ្នាក្នុងចំណោមអង្គការដែលធ្វើការលើវិស័យនេះ។

៤៩. នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៦ រដ្ឋាភិបាលបានប្រកាសបញ្ចប់ការពិនិត្យមើលឡើងវិញដ៏ទូលំទូលាយលើសម្បទានដីសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ដែលបានដាក់ដំណើរការកាលពីក្នុងឆ្នាំ ២០១៤ ហើយសន្យាផ្ទេរផ្ទៃដីជិត១លានហិកតានៃដីសម្បទានដែលបានដកហូត ឲ្យទៅដល់គ្រួសារក្រីក្រវិញ។ យោងតាមព័ត៌មានដែលអាចរកបានជាសាធារណៈ មានសម្បទានដីចំនួន ២៣០ ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងបរិស្ថាន ត្រូវបានពិនិត្យមើលឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ កង្វះព័ត៌មានជាក់

[16] ការិយាល័យOHCHR ការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅកម្ពុជា៖ តម្លៃមនុស្ស ផលប៉ះពាល់ និងដំណោះស្រាយ (ភ្នំពេញ ២០១២)។ អាចរកបានពី http://cambodia.ohchr.org/sites/default/files/Thematic-reports/Resettlement_Study-28_Feb_2012_Eng.pdf.

លាក់ ដូចជាកូអរដោនេភូមិសាស្ត្រនៃទីតាំងដីដែលបានដកហូតពីសម្បទានដីសេដ្ឋកិច្ចនីមួយៗ ឬអត្តសញ្ញាណនៃស្ថាប័នរដ្ឋដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងដីដែលត្រូវបានដកហូត ធ្វើឲ្យការតាមដានលើបញ្ហានេះ ជួបការលំបាក។

៥០. ការិយាល័យOHCHR និងអង្គការមិនមែនរដ្ឋាភិបាល បានជួបប្រជុំគ្នាពីរដងនៅក្នុងឆ្នាំ២០១៦ ដើម្បីស្វែងរកវិធីដែលអាចជួយដល់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងសហគមន៍រងផលប៉ះពាល់ផង ទទួលបានបច្ចុប្បន្នភាពអំពីស្ថានភាពនេះ។ ជាលទ្ធផល អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើប្រភពទិន្នន័យចំហរ គឺអង្គការទិន្នន័យអំពីការអភិវឌ្ឍ(ODC) បានផលិតនូវការវិភាគមួយអំពីសម្បទានដីសេដ្ឋកិច្ចដែលបានដកហូតនិងកាត់បន្ថយទំហំ តាមរយៈការប្រើប្រាស់ប្រភពទិន្នន័យ ដែលយកចេញមកពីការងារតាមដានជាទៀងទាត់របស់ខ្លួនលើទិន្នន័យរបស់រដ្ឋាភិបាល និងឯកសារច្បាប់ពាក់ព័ន្ធដែលទទួលបាន ដោយមានការឧបត្ថម្ភគាំទ្ររបស់ការិយាល័យOHCHR។ សម្បទានដីសេដ្ឋកិច្ចចំនួន ២៥៧ ដែលបានកត់ត្រានៅក្នុងមូលដ្ឋានទិន្នន័យរបស់ខ្លួន អង្គការទិន្នន័យអំពីការអភិវឌ្ឍ បានរកឃើញថា មកដល់ត្រឹមខែមករា ឆ្នាំ ២០១៧ មានសម្បទានដីសេដ្ឋកិច្ចចំនួន ៣២ ត្រូវបានដកហូត សម្បទានដីសេដ្ឋកិច្ចចំនួន ១៣៤ មិនមានភស្តុតាងពីការកែសម្រួលទំហំផ្ទៃដី និងសម្បទានដីសេដ្ឋកិច្ចចំនួន ៤ ត្រូវបានកាត់បន្ថយទំហំ បន្ទាប់ពីការដកហូត ហើយសម្បទានដីសេដ្ឋកិច្ចចំនួន ៨៧ ផ្សេងទៀត ត្រូវបានកាត់បន្ថយទំហំ។

៥១. ការិយាល័យOHCHR បានសម្របសម្រួលកិច្ចប្រជុំតាមដានមួយ ដើម្បីពិភាក្សា បំពេញបន្ថែម និងផ្តល់សុពលភាពលើតួលេខរបស់អង្គការទិន្នន័យអំពីការអភិវឌ្ឍ ហើយបន្ទាប់ពីកិច្ចប្រជុំនេះ ការិយាល័យOHCHR បានបញ្ជូនទិន្នន័យទាំងនេះទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងខែមិនា ដោយស្នើសុំការឆ្លើយតបចំពោះទិន្នន័យនេះដែលអាចមានភាពខុសគ្នាជាមួយតួលេខរបស់ក្រសួង និងស្នើសុំនូវព័ត៌មានអំពីការបែងចែកដីសម្បទានដែលបានដកហូត។ យោងតាមការឆ្លើយតបរបស់ក្រសួង ដែលការិយាល័យOHCHR ទទួលបាននៅក្នុងខែឧសភា មានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ២២៩ ដែលកំពុងនៅមានសុពលភាព គ្របដណ្តប់លើផ្ទៃដីសរុប ១,៥៣ លានហិកតា ស្ថិតនៅក្នុងខេត្តចំនួន១៨។ ក្រសួងក៏បានផ្តល់ព័ត៌មានអំពីតួលេខនៃផ្ទៃដីបានឈូសឆាយឬបានដាំដុះ ប្រព័ន្ធផ្លូវបានសាងសង់ ឬកំលាំងពលកម្មដែលបានប្រើប្រាស់។ ក្រសួងមិនបានផ្តល់ព័ត៌មានអំពីទីតាំង និងទំហំនៃសម្បទានដីសេដ្ឋកិច្ចដែលបានកាត់បន្ថយទំហំឬដកហូត ឬក៏អំពីដំណើរនៃការបែងចែកដីឡើងវិញឡើយ។

៥២. នៅក្នុងឆ្នាំ ២០១៦ ការិយាល័យOHCHR បានធ្វើការសិក្សាវាយតម្លៃផ្អែកលើសិទ្ធិមនុស្សនៃសម្បទានដីសង្គមកិច្ចចំនួន៦កន្លែង នៅផ្នែកផ្សេងៗក្នុងប្រទេសកម្ពុជា។ សេចក្តីព្រាងរបាយការណ៍នៃការសិក្សាវាយតម្លៃនេះ ត្រូវបានសរសេរបញ្ចប់នៅដើមឆ្នាំ២០១៧ ហើយបានដាក់បង្ហាញជាផ្លូវការសម្រាប់ការពិនិត្យពិភាក្សានៅឯកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិមួយដែលបានធ្វើឡើងនៅក្នុងខែកុម្ភៈ និងមានការចូលរួមដោយតំណាងមកពីក្រសួងរៀបចំដែនដី ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកិច្ចការនារី អាជ្ញាធរថ្នាក់ក្រោមជាតិ និងតំណាងសហគមន៍មកពី ៦ខេត្ត ផងដែរ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលសកម្មក្នុងវិស័យនេះ។ យោបល់ និងធាតុចូលទាំងឡាយបានមកពីកិច្ចប្រជុំពិគ្រោះយោបល់នេះ ត្រូវបាន

ច្រចាច់បញ្ចូលទៅក្នុងសេចក្តីព្រាងរបាយការណ៍ថ្មីមួយទៀត ដែលនឹងត្រូវសរសេរបញ្ចប់សម្រាប់ការបោះពុម្ពផ្សាយនាពេលខាងមុខ នៅក្នុងឆ្នាំ២០១៧។

៥៣. នៅក្នុងខែ ឧសភា ការិយាល័យOHCHR បានផ្តល់ជំនួយហិរញ្ញវត្ថុដល់អង្គការទិន្នន័យអំពីការអភិវឌ្ឍ ដើម្បីចងក្រងព័ត៌មានច្បាប់ និងព័ត៌មានសាធារណៈផ្សេងៗស្តីអំពីសម្បទានដីសង្គមកិច្ច និងការបង្កើតនូវផែនទីអន្តរកម្មតាមអនឡាញ។ សម្បទានដីសង្គមកិច្ចខ្លះត្រូវបានជាប់គាំងនៅក្នុងជម្លោះរ៉ាំរ៉ៃ ចាប់តាំងពីពេលចាប់ផ្តើមនៃកម្មវិធី ដោយសារតែដីដែលបានផ្តល់ជាសម្បទានសង្គមកិច្ចនោះ មានការកាន់កាប់រួចទៅហើយ។ បណ្តឹងដែលទទួលបានតាមរយៈអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ បង្ហាញឲ្យឃើញពីហានិភ័យនៃការកើតឡើងនូវជម្លោះដីធ្លីនៅក្នុងគម្រោងសម្បទានដីសង្គមកិច្ចថ្មី ដែលជាផែនការផ្តួចផ្តើមឡើងដោយធនាគារពិភពលោក ។ ផែនទីនិងការវិភាគដែលផលិតឡើងដោយ UNOSAT បានបង្ហាញថា ដីក្នុងគម្រោងនោះមានការប្រើប្រាស់ និងអភិវឌ្ឍក្នុងរយៈពេល៣០ឆ្នាំមកនេះ។ ព័ត៌មានអំពីការវិភាគនេះ ត្រូវបានចែករំលែកជាមួយធនាគារពិភពលោក ដើម្បីជួយដល់ស្ថាប័ននេះពិនិត្យមើលឡើងវិញនូវតំបន់គោលដៅទាំងនោះ។

៥៤. ការវិនិយោគផ្ទាល់ពីបរទេស និងក្នុងស្រុក គឺជាប្រភពដ៏សំខាន់មួយនៃកំណើនសេដ្ឋកិច្ចជាបន្តរបស់កម្ពុជា និងការរីកចម្រើនជាលំដាប់របស់ខ្លួនឆ្ពោះទៅរកឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប។ ការវិនិយោគនេះ មានជាប់ទាក់ទងផងដែរទៅនឹងការរំលោភសិទ្ធិរបស់សហគមន៍មូលដ្ឋានជាច្រើន។ ការិយាល័យOHCHR បានបន្តនូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីជម្រុញឲ្យមានការយល់ដឹងពីគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងការអនុវត្តគោលការណ៍ណែនាំទាំងនេះនៅក្នុងប្រទេសកម្ពុជា ដោយធ្វើការងារនេះដោយផ្ទាល់ មិនត្រឹមតែជាមួយធុរកិច្ច និងបុគ្រសម្ព័ន្ធរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែធ្វើការផងដែរជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងតំណាងសហគមន៍ រួមទាំងជនជាតិដើមភាគតិច។ ការិយាល័យOHCHR បានរៀបចំ ចូលរួមចំណែក ឬបានផ្តល់ឲ្យមានជាសិក្ខាសាលា កិច្ចប្រជុំពិគ្រោះយោបល់ និងវគ្គបណ្តុះបណ្តាលនានាលើប្រធានបទនេះ ដែលមានការចូលរួមពីភាគីពាក់ព័ន្ធចំនួន ៣៥៩ នាក់ នៅទូទាំងប្រទេសកម្ពុជា។ ការិយាល័យ OHCHR បានគាំទ្រដល់សកម្មភាពកសាងសមត្ថភាព ដើម្បីធ្វើឲ្យមានភាពប្រសើរឡើងនូវការទទួលបាននិងប្រើប្រាស់យន្តការក្រៅប្រព័ន្ធតុលាការពីសំណាក់សង្គមស៊ីវិលនិងសហគមន៍ ដើម្បីពិភាក្សារកដំណោះស្រាយចំពោះផលប៉ះពាល់សិទ្ធិមនុស្សដែលជាប់ទាក់ទងនឹងធុរកិច្ចនៅកម្រិតប្រតិបត្តិការ កម្រិតជាតិ និងអន្តរជាតិ។

៥៥. ទាក់ទងចំនុចនេះ ការិយាល័យOHCHR បានបន្តការប្រាស្រ័យទាក់ទងរបស់ខ្លួនជាមួយក្រុមហ៊ុនកៅស៊ូមកពីអឺរ៉ុបមួយ ដែលជាអ្នកទទួលផលពីដីសម្បទានសេដ្ឋកិច្ចនៅក្នុងខេត្តមណ្ឌលគិរី ដើម្បីគាំទ្រដល់កិច្ចចរចាររវាងក្រុមហ៊ុន និងសហគមន៍ជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ ហើយក៏គាំទ្រផងដែរដល់ដំណើរការនៃកិច្ចពិភាក្សាត្រីភាគី (មានបន្ថែមអាជ្ញាធរមូលដ្ឋាន) ដែលបានបង្កើតឡើងដោយគំនិតផ្តួចផ្តើមរបស់ភាគីពាក់ព័ន្ធនៅមូលដ្ឋាន។ ជាមួយនឹងជំនាញចរចាររបស់តំណាងជនជាតិដើមភាគតិចដែលត្រូវបានពង្រឹង តាមរយៈវគ្គ បណ្តុះបណ្តាលរៀបចំឡើងដោយការិយាល័យOHCHR ហើយគិតមកត្រឹមខែមិថុនា ឆ្នាំ២០១៧ កិច្ច

ព្រមព្រៀងសំណង ត្រូវបានបញ្ចប់ពាក់ព័ន្ធនឹងទីតាំងព្រៃតំណមមួយកន្លែង និងមានការបង្ហាញពីការប្តេជ្ញាចិត្តច្បាស់លាស់ និងការកំណត់ពេលជាក់លាក់ពីក្រុមហ៊ុន ដើម្បីពិនិត្យមើលឡើងវិញនូវរាល់ការទាមទារដីដែលកំពុងរង់ចាំការដោះស្រាយ។ កិច្ចប្រជុំពហុភាគីពាក់ព័ន្ធចំនួនបីដែលមានការចូលរួមពីតំណាងជនជាតិដើមភាគតិច អាជ្ញាធរមូលដ្ឋាន តំណាងមកពីសម្បទានិកមួយចំនួន អង្គការមិនមែនរដ្ឋាភិបាល អង្គការសហប្រជាជាតិ និងភ្នាក់ងារអភិវឌ្ឍន៍ ត្រូវបានរៀបចំធ្វើឡើង ដើម្បីពិនិត្យមើលនូវវឌ្ឍនភាពនានា។

៥៦. ការិយាល័យOHCHR បានបន្តធ្វើការជាមួយក្រសួងចំនួនបី ដែលពាក់ព័ន្ធក្នុងការគាំទ្រដល់ដំណើរការប័ណ្ណកម្មសិទ្ធិសមូហភាពសហគមន៍ជនជាតិដើមភាគតិច (ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) អាជ្ញាធរថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល ដើម្បីគាំទ្រដល់ជនជាតិដើមភាគតិច ដាក់ពាក្យស្នើរសុំប័ណ្ណកម្មសិទ្ធិសមូហភាព ដែលជាមធ្យោបាយចម្បងមួយសម្រាប់ពួកគាត់ទាមទារ និងការពារសិទ្ធិរបស់ខ្លួន។ ទន្ទឹមនឹង លទ្ធភាពរបស់ជនជាតិដើមភាគតិច ធ្វើជាម្ចាស់ស្របច្បាប់លើដីធ្លីជាលក្ខណៈសមូហភាពទៅតាមទំនៀមទម្លាប់ និងប្រពៃណីរបស់ខ្លួន បង្កើតឡើងនូវឧទាហរណ៍ជាវិជ្ជមានមួយនៅក្នុងតំបន់អាស៊ីនិងទីកន្លែងដទៃទៀត ប៉ុន្តែទំហំនៃភាពស្មុគ្រស្មាញផ្នែកច្បាប់និងរដ្ឋបាលនិងដំណើរការដែលប្រើរយៈពេលយូរនិងតម្លៃចំណាយខ្ពស់ ស្តែងឲ្យឃើញថាមានតែសហគមន៍ជនជាតិដើមភាគតិចចំនួន ១៤ ប៉ុណ្ណោះដែលបានទទួលប័ណ្ណកម្មសិទ្ធិសមូហភាព ដោយគិតត្រឹមខែមិថុនា ឆ្នាំ២០១៧។ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ការិយាល័យ OHCHR បានធ្វើការសិក្សាវាយតម្លៃលើលទ្ធភាពនៃការធ្វើឲ្យដំណើរការនេះមានប្រសិទ្ធិភាព និងធ្វើឲ្យមានភាពងាយស្រួលដល់សហគមន៍ជនជាតិដើមភាគតិច ដើម្បីចូលរួមក្នុងដំណើរការនេះនិងក្នុងទំហំលទ្ធភាពរបស់ពួកគាត់។ ផ្អែកលើដំណើរទស្សនកិច្ចនៅសហគមន៍ដែលមានជនជាតិដើមភាគតិច ទំពួន កាវ៉ែត ស្ទួយ ប៊ូនង ស្អៀង គួយ ជង និងព័រ នៅក្នុងខេត្តចំនួន ១១ ហើយនិងក្នុងកិច្ចពិគ្រោះយោបល់ជាមួយក្រសួងចំនួនបី និងបណ្តាអង្គការជនជាតិដើមភាគតិច ការិយាល័យOHCHR បានរៀបចំនូវឯកសារពិគ្រោះយោបល់មួយដែលនឹងត្រូវបង្ហាញជាផ្លូវការសម្រាប់ការពិភាក្សានៅពេលខាងមុខក្នុងឆ្នាំ២០១៧ នេះ។

៥៧. ការិយាល័យOHCHR នៅតែបន្តសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងអាជ្ញាធរ ក្នុងខេត្តកោះកុង ដើម្បីបញ្ចប់ការងារចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជងទាំង៨សហគមន៍នៅក្នុងតំបន់អារ៉ែង ជាតំបន់ដែលមានជម្លោះដីធ្លីក្នុងទ្រង់ទ្រាយធំមួយនាប៉ុន្មានឆ្នាំថ្មីៗនេះ។ ចាប់ពីខែឧសភា ឆ្នាំ២០១៧ ការិយាល័យOHCHR បានចាប់ផ្តើមដំណើរការនូវកិច្ចសហការស្រដៀងគ្នានេះដែរ ជាមួយក្រសួង និងអាជ្ញាធរខេត្តក្រចេះ ដើម្បីគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិចប៊ូនង ដែលសហគមន៍នេះជាប់ផុងក្នុងជម្លោះដីធ្លីទ្រង់ទ្រាយធំមួយនៅក្នុងស្រុកស្នួល។ ការិយាល័យOHCHR បានរៀបចំនូវការផលិតវីដេអូមួយដើម្បីពន្យល់ពីនីតិវិធីនៃជំហានដំបូងរបស់ដំណើរការប័ណ្ណកម្មសិទ្ធិសមូហភាព សម្រាប់យកទៅប្រើប្រាស់នៅក្នុងវគ្គបណ្តុះបណ្តាលនាពេលអនាគត។ នៅក្នុងខែតុលា ឆ្នាំ២០១៦ ការិយាល័យOHCHR បានសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ផ្តល់ជូននូវការបណ្តុះបណ្តាលចំនួនពីរវគ្គដល់មន្ត្រី

មូលដ្ឋានសរុបចំនួន១០០នាក់ ជាវគ្គបណ្តុះបណ្តាលទីមួយក្នុងចំណោមវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ចំនួនពីរ ធ្វើឡើងសម្រាប់អាជ្ញាធរថ្នាក់ក្រោមជាតិជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ។

៥៨. ប័ណ្ណកម្មសិទ្ធិដីសមូហភាព មានគោលបំណងផ្តល់នូវសុវត្ថិភាពសិទ្ធិកាន់កាប់ជាអចិន្ត្រៃយ៍ដល់សហគមន៍ទាំងមូល និងជួយរក្សានូវអត្តសញ្ញាណ និងបូរណភាពរបស់ពួកគាត់ ពីព្រោះដីស្ថិតក្រោមប័ណ្ណកម្មសិទ្ធិសមូហភាព អាចត្រូវលក់ដូរបានតែក្នុងចំណោមសមាជិកសហគមន៍ពួកគាត់តែប៉ុណ្ណោះ។ នេះគឺជាការផ្តល់នូវការការពារ ប៉ុន្តែក៏ដើម្បីទប់ស្កាត់ការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិជាការដាក់បញ្ចាំផងដែរ ដែលអាចបង្អាក់សហគមន៍ដែលមានប័ណ្ណកម្មសិទ្ធិពីការទទួលបានសេវាហិរញ្ញវត្ថុរបស់ធនាគារ និងបង្អាក់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ពួកគាត់។ ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហានេះ ការិយាល័យOHCHR បានផ្តួចផ្តើមធ្វើការស្ទង់មតិស៊ីជម្រៅមួយសម្រាប់សហគមន៍ខ្លះក្នុងចំណោមសហគមន៍ចំនួន១៤ ដែលមានប័ណ្ណកម្មសិទ្ធិសមូហភាព ដើម្បីធ្វើការប្រៀបធៀប ក្នុងចំណោមបញ្ហាផ្សេងៗ អំពីកម្រិតនៃការទទួលបានហិរញ្ញវត្ថុរបស់ពួកគេ ទៅនឹងការទទួលបានហិរញ្ញវត្ថុរបស់អ្នកភូមិជាជនជាតិខ្មែរ។

៥៩. ការិយាល័យOHCHR បានបន្តចូលរួមចំណែកដល់ការអភិវឌ្ឍន៍ក្របខណ្ឌគោលនយោបាយ និងច្បាប់ទាក់ទងនឹងវិស័យដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ។ ការិយាល័យOHCHR បានចូលរួមក្នុងកិច្ចពិគ្រោះយោបល់លើក្រមបរិស្ថានដែលដឹកនាំដោយក្រសួងបរិស្ថាន និងចូលរួមក្នុងកិច្ចពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីដីកសិកម្ម ដែលដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយនិងផ្តល់យោបល់លើភាពសុខដុមកម្មជាមួយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនៃសេចក្តីព្រាងច្បាប់ទាំងពីរ។ ធាតុចូលមួយចំនួនពីការិយាល័យOHCHR ត្រូវបានឆ្លុះបញ្ចាំងក្នុងវិសាលភាពមួយចំនួននៃសេចក្តីព្រាងក្រមបរិស្ថានចុងក្រោយដែលចេញក្នុងខែឧសភា ឆ្នាំ២០១៧ នេះ ជាពិសេសលើគោលការណ៍សិទ្ធិមនុស្សស្តីពីការយល់ព្រមដោយសេរី និងដោយទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយជាមុន ស្តីពីការតាំងទីលំនៅថ្មី ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មាន។ ការិយាល័យOHCHR បានគាំទ្រផងដែរដល់កិច្ចពិគ្រោះយោបល់ថ្នាក់ក្រោមជាតិមួយលើសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការចូលរួមជាសាធារណៈក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA) និងសម្របសម្រួលឲ្យមានការចូលរួមរបស់តំណាងជនជាតិដើមភាគតិចជាពិសេស។

៦០. ការិយាល័យOHCHR បានបន្តលើកកម្ពស់សិទ្ធិស្ត្រីលើដីធ្លី សុវត្ថិភាពខាងការកាន់កាប់ លំនៅឋានសមរម្យ និងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលមានភាពប្រទាក់ក្រឡាគ្នា។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៧ ការិយាល័យOHCHR និងអង្គការសហប្រជាជាតិសម្រាប់សមភាពយេនឌ័រ និងកាពង្រឹងអំណាចដល់ស្ត្រី(UN Women) បានសហការរៀបចំវគ្គបណ្តុះបណ្តាលមួយស្តីពីពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី ដល់ស្ត្រីចំនួន ២៣ នាក់ មកពីក្រុមដែលធ្វើការយ៉ាងសកម្មនៅកម្រិតមូលដ្ឋាន ដើម្បីគាំទ្រដល់ស្ត្រីងាយរងគ្រោះនៅក្នុង វិស័យសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច និងសង្គម។

## VI. ទំនាក់ទំនងនិងព័ត៌មានសិទ្ធិមនុស្ស

៦១. ការិយាល័យ OHCHR បានបន្តការងាររបស់ខ្លួន ផ្នែកផ្សព្វផ្សាយព័ត៌មាននិងទំនាក់ទំនងសាធារណៈយ៉ាងទូលំទូលាយដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗជាច្រើន។ ការិយាល័យ OHCHR បានបោះពុម្ពផ្សាយជាភាសាខ្មែរនូវសៀវភៅ ឬឯកសារបោះពុម្ពផ្សាយជាច្រើនអំពីសិទ្ធិមនុស្ស។ នៅក្នុងឆ្នាំនេះ ការិយាល័យOHCHR បានធ្វើការចែកចាយសៀវភៅ ឬឯកសារច្រើនជាង ៦៧,០០០ ក្បាល ដល់ស្ថាប័នផ្សេងៗក្នុងជួររដ្ឋាភិបាល សាកលវិទ្យាល័យ អង្គការសង្គមស៊ីវិល ឯកត្តបុគ្គល ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការដទៃផ្សេងទៀត។ ការិយាល័យOHCHR បានបន្តការងាររបស់ខ្លួនដែលពេញនិយម "បើកទ្វារថ្ងៃសុក្រ" ដែលអនុញ្ញាតឲ្យសាធារណជនទូទៅមកទាក់ទងស្នើសុំសៀវភៅ ឬឯកសារបោះពុម្ពផ្សាយដោយឥតគិតថ្លៃ។ ការិយាល័យOHCHR ប្រើហ្វេសប៊ុក និងទ្វីតធឺរ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីស្ថានការណ៍វិវត្តខាងសិទ្ធិមនុស្សសកម្មភាពរបស់ខ្លួន និងព័ត៌មានពីយន្តការសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធនឹងប្រទេសកម្ពុជា។ ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៦ មក ប្រិយមិត្តអ្នកតាមហ្វេសប៊ុករបស់ការិយាល័យOHCHR បានកើនឡើងមួយភាគបីគឺរហូតដល់ទៅ ៧,៨២០ នាក់។ វេបសាយដែលមានពីរភាសារបស់ការិយាល័យOHCHR បានទាក់ទាញអ្នកទស្សនាច្រើនជាង ១០,០០០ នាក់។

៦២. ការិយាល័យ OHCHR បានពង្រីកការងាររបស់ខ្លួនខាងសោតទស្សន៍ និងវីដេអូ។ ការិយាល័យ OHCHR បានបកប្រែជាភាសាខ្មែរនូវវីដេអូចំនួនបីចុងក្រោយពីយុទ្ធនាការពិភពលោករបស់ការិយាល័យOHCHR "អ.ស.ប ស្មើភាពគ្នានឹងសេរី" ដើម្បីគាំទ្រដល់សិទ្ធិមនុស្សស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ ហើយនិងមនុស្សភេទពីរ និងបង្កើតជាវីដេអូខ្លីៗសម្រាប់ការអប់រំអំពីច្បាប់ស្តីពីបាតុកម្មដោយសន្តិភាព។ កម្មវិធីវិទ្យុ "សិទ្ធិមនុស្ស ៣៦៥ ថ្ងៃ" របស់ខ្លួន ដែលរួមមានកម្មវិធីវិទ្យុអន្តរកម្មចំនួនប្រាំបីលើប្រធានបទផ្សេងៗគ្នា ជាមួយវាគ្មិនមកពីរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ធុរកិច្ច អង្គភាពអង្គការសហប្រជាជាតិ និងអ្នកជំនាញផ្សេងទៀត។ ការិយាល័យOHCHR បានចូលរួមផងដែរ ក្នុងកម្មវិធីវិទ្យុដែលរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ។ កម្មវិធីនេះ ត្រូវបានផលិតជាភាសាជនជាតិដើមភាគតិចព្នង និងភាសាចារ៉ាយ។ កម្មវិធីឆ្លើយឆ្លងអន្តរកម្មជាសម្លេង(IVR) របស់ខ្លួន ស្តីពី "ការការពារ ការគោរព និងដំណោះស្រាយ" ក្របខ័ណ្ឌសិទ្ធិមនុស្ស និងធុរកិច្ច ដែលបានប្រកាសបើកជាផ្លូវការកាលពីឆ្នាំមុន ។

៦៣. ការិយាល័យOHCHR បានរំលឹកខួបទិវាអន្តរជាតិសំខាន់ៗ រួមទាំង ទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក យុទ្ធនាការ ១៦ ថ្ងៃ ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី ទិវាអង្គការសហប្រជាជាតិ ទិវាសិទ្ធិមនុស្ស ទិវាពលកម្មអន្តរជាតិ ទិវាសេរីភាពសារព័ត៌មានពិភពលោក និងទិវាអន្តរជាតិប្រឆាំងការស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកប្តូរភេទ និងមនុស្សភេទពីរ។ ការិយាល័យOHCHR បានរៀបចំ ឬចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗដែលដឹកនាំដោយអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ដទៃទៀត និងអង្គការសង្គមស៊ីវិល បានចែកចាយឯកសារព័ត៌មាន និងឯកសារផ្សព្វផ្សាយ និងបានចូលរួមផ្តល់ជាមតិយោបល់ផ្សេងៗ

ដើម្បីលើកម្ពស់ការយល់ដឹងដល់សាធារណៈជន។ សម្រាប់ទិវាសិទ្ធិមនុស្ស ការិយាល័យ OHCHR បានរៀបចំឲ្យមានការប្រកួតឆ្លើយសំណួរតាមអនឡាញ តាមរយៈទំព័រហ្វេសប៊ុករបស់ខ្លួន ដែលមានអ្នកប្រើប្រាស់ជាង ៣៣៥,០០០ នាក់។

## VII. គាំទ្រការចូលរួមជាមួយយន្តការសិទ្ធិមនុស្សអន្តរជាតិ

៦៤. ការលើកកម្ពស់ការយល់ដឹងអំពីបទដ្ឋាន និងយន្តការសិទ្ធិមនុស្ស គឺជាភារកិច្ចស្នូលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR)។ ការិយា-ល័យនេះបន្តលើកកម្ពស់ដល់ការផ្តល់សច្ចាប័នលើសន្ធិសញ្ញានានាដោយប្រទេសកម្ពុជា រួមមានអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ ដែលសមស្របជាពិសេសសម្រាប់កម្ពុជា ដោយសារតែប្រទេសនេះមានពលរដ្ឋទេសន្តប្រវេសន៍យ៉ាងច្រើននិងងាយរងគ្រោះ នៅធ្វើការក្នុងប្រទេសជិតខាងនិងប្រទេសផ្សេងៗទៀត។

៦៥. នៅខែមករា ឆ្នាំ២០១៧ កម្ពុជាបានដាក់របាយការណ៍អនុវត្តន៍បន្ត ឆ្លើយតបនឹងសេចក្តីសង្កេតសន្និដ្ឋាន របស់គណៈកម្មាធិការសិទ្ធិមនុស្សឆ្នាំ២០១៥ ដោយផ្តោតលើអនុសាសន៍ទាក់ទងនឹងការសំលាប់ក្រៅប្រព័ន្ធតុលាការ ការបង្ការទារុណកម្ម និងសេរីភាពក្នុងការបញ្ចេញមតិ។ របាយការណ៍នានាដែលហួសកាលកំណត់ ដាក់ជូនគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ គណៈកម្មា-ធិការស្តីពីសិទ្ធិជនពិការ និងគណៈកម្មាធិការស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ក៏ដូចជាការឆ្លើយតបទៅនឹងបញ្ជីសំណួររបស់គណៈកម្មាធិការប្រឆាំងទារុណកម្ម នៅមិនទាន់បានដាក់ជូននៅឡើយ។ ការិយាល័យOHCHR បន្តគាំទ្រផ្នែកបច្ចេកទេសរបស់ខ្លួនដល់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា(CHRC) ក្រុមប្រឹក្សាសកម្មភាពជនពិការ និងក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារអំពីលក្ខណ្ឌតម្រូវនានាក្នុងការធ្វើរបាយការណ៍ទាំងនេះ។ ដោយមានការគាំទ្រពីកម្មវិធីកសាងសមត្ថភាពស្ថាប័នសន្ធិសញ្ញា ការិយាល័យOHCHR បានផ្តួចផ្តើមគំនិតឲ្យមានវគ្គបណ្តុះបណ្តាលជាស៊េរីមួយនៅខែឧសភា ឆ្នាំ២០១៧ ដោយសហការជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា(CHRC) សំដៅបង្កើនសមត្ថភាពដល់មន្ត្រីដែលពាក់ព័ន្ធក្នុងការរៀបចំព្រាងរបាយការណ៍ទៅស្ថាប័នសន្ធិសញ្ញានានា។

៦៦. ការិយាល័យOHCHR បានអនុវត្តបន្តជាមួយក្រសួងមហាផ្ទៃលើរបាយការណ៍នៃដំណើរទស្សនកិច្ចចំនួន ២ លើក របស់អនុគណៈកម្មាធិការបង្ការទារុណកម្ម និងសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីយន្តការបង្ការថ្នាក់ជាតិ ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពលើអនុក្រឹត្យដែលមានសព្វថ្ងៃ។ ដូចដែលបានផ្តល់ការវិភាគដោយការិយាល័យOHCHR សេចក្តីព្រាងព្រះរាជក្រឹត្យនេះក៏មិនបានធានាអំពីឯករាជ្យភាពនៃយន្តការ ពីអាជ្ញាធរ ដែលមានអាណត្តិក្នុងការឃ្លាំមើលដែរ។

៦៧. ដើម្បីពង្រឹងដល់ការអនុវត្តជាក់ស្តែងនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ ការិយាល័យOHCHR បានគាំទ្រវគ្គបណ្តុះបណ្តាលរៀបចំដោយក្រុមប្រឹក្សាសកម្មភាពជនពិការ សម្រាប់មន្ត្រីមូលដ្ឋាននៃក្រុមប្រឹក្សានេះនៅខេត្តកំពត។ នេះគឺជាលើកទីមួយនៃវគ្គបណ្តុះបណ្តាលដែលមានផែនការរៀបជាស៊េរីសំរាប់មន្ត្រីមូលដ្ឋាននៅគ្រប់ខេត្ត ហើយក៏បានផ្តល់ឱកាសឱ្យការិយាល័យOHCHR

ឃើញពីវិធីនៃការបណ្តុះបណ្តាលរបស់គ្រូបង្គោលដែល ខ្លួនបានផ្តល់ឱ្យក្រុមប្រឹក្សាសកម្មភាពជនពិការកាលពីមុន ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីបណ្តុះបណ្តាល នៅតាមខេត្តនាពេលក្រោយៗទៀត។

៦៨. ការិយាល័យOHCHR បានធ្វើបច្ចុប្បន្នភាពនៃការបោះពុម្ពជាពីរភាសានៃកម្រងអនុសាសន៍ពីការពិនិត្យឡើងវិញជាសកលតាមកាលកំណត់UPR សំរាប់កម្ពុជា ការពិនិត្យឡើងវិញរបស់ស្ថាប័នសន្ធិសញ្ញា និងនីតិវិធីពិសេស ដោយមានដាក់បញ្ចូលសេចក្តីយោងដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផង។

៦៩. ការិយាល័យOHCHR បានជួយគាំទ្រដល់ដំណើរទស្សនកិច្ចលើកទី៣ របស់អ្នករាយការណ៍ពិសេសស្តីពី ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី១០ដល់១៩ ខែតុលា ឆ្នាំ២០១៦) ដោយអ្នកស្រីបានបន្តការយកចិត្តទុកដាក់លើប្រភេទជាក់លាក់នៃការរើសអើង ខណៈដែលអ្នកស្រីកំពុងពិនិត្យឡើងវិញ អំពីស្ថានភាពសិទ្ធិមនុស្សដ៏សំខាន់នេះ។

៧០. ការិយាល័យOHCHR បានជួយគាំទ្រដល់ដំណើរទស្សនកិច្ចស្វែងយល់របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពជួបប្រជុំដោយសន្តិវិធី និងសិទ្ធិសេរីភាពខាងសមាគម នៅខែធ្នូ ឆ្នាំ២០១៦ និងអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស នៅខែឧសភា ឆ្នាំ២០១៧។ ការិយាល័យOHCHR បានបន្តបកប្រែ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវរបាយ-ការណ៍ គោលការណ៍ណែនាំ និងលិខិតុបករណ៍ផ្សេងៗ ដែលតាក់តែងដោយនីតិវិធីពិសេស ដែលពាក់ព័ន្ធនឹងប្រទេសកម្ពុជា ហើយនាពេលថ្មីៗនេះ បានបកប្រែជាភាសាខ្មែរនូវ "គោលការណ៍ទាំង១០ ស្តីពីការគ្រប់គ្រងបាតុកម្មដោយសន្តិវិធី" របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពជួបប្រជុំដោយសន្តិវិធី និងសិទ្ធិសេរីភាពខាងសមាគម [17] និងរបាយការណ៍ឆ្នាំ២០១៣ របស់លោកដាក់ជូនមហាសន្និបាត ស្តីពីការអនុវត្តសិទ្ធិទាំងនេះក្នុងបរិបទនៃការបោះឆ្នោត។ [18]

## VIII. បញ្ហាសិទ្ធិមនុស្សនៅក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ

៧១. ការសម្របសម្រួលនៃសកម្មភាពលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅទូទាំងប្រព័ន្ធអង្គការសហប្រជាជាតិគឺជាទំនួលខុសត្រូវដ៏ចម្បងរបស់ការិយាល័យOHCHR ។ ការិយាល័យនេះបានធ្វើជាប្រធានក្រុមខាងវិស័យសិទ្ធិមនុស្ស ចាប់តាំងពីពេលដែលក្រុមនេះ ត្រូវបានបង្កើតនៅក្នុងឆ្នាំ២០១៤។ នេះជាក្រុមដ៏សកម្មមួយដែលមានសមាជិកចំនួន១៣ រូប តំណាងឲ្យក្រុមទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ដែលជួបប្រជុំគ្នារៀងរាល់ពីរខែម្តង ដើម្បីពិនិត្យឡើងវិញ អំពីកង្វល់ដែលកើតមានលើបញ្ហាសិទ្ធិមនុស្ស ជួយសម្រួលដល់គំនិតផ្តួចផ្តើមអន្តរទីភ្នាក់ងារ ដើម្បីដោះស្រាយបញ្ហាកង្វល់ ធ្វើការផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីយន្តការសិទ្ធិមនុស្សអន្តរជាតិ និងឆ្លើយតបទៅនឹងសំណើសុំមតិយោបល់អំពីគំនិតផ្តួចផ្តើមសិទ្ធិមនុស្សក្នុងតំបន់ និងនៅទូទាំងពិភពលោក។

---

[17] សូមមើល www.ohchr.org/Documents/Issues/FAssociation/10PrinciplesProperManagementAssemblies.pdf.

[18] សូមមើលរបាយការណ៍លេខ A/68/299

៧២. បន្ទាប់ពីមានសន្និសីទថ្នាក់ជាតិឆ្នាំ២០១៥ ស្តីពីជនរស់នៅតាមចិញ្ចើមផ្លូវ[19] ក្រុមការងារវិស័យសិទ្ធិមនុស្សបានបន្តសម្របសម្រួលដំណើរទស្សនកិច្ចអន្តរទីភ្នាក់ងារ ទៅកាន់មជ្ឈមណ្ឌលសង្គមកិច្ចដ៏សំខាន់មួយនៅរាជធានីភ្នំពេញ។ ដោយសារតែស្ថានភាពក្នុងពន្ធនាគារមានការចង្អៀតណែនខ្លាំង ក្រោយពីមានយុទ្ធនាការប្រឆាំងគ្រឿងញៀន។ ក្រុមការងារបច្ចេកទេសខាងជនរស់នៅតាមចិញ្ចើមផ្លូវ ត្រូវបានបង្កើតឡើងក្រោយពីមានសន្និសីទឆ្នាំ២០១៥ ស្ថិតក្រោមអធិបតីភាពរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយដែលមានបំណងអញ្ជើញមកជួបប្រជុំនូវអាជ្ញាធររដ្ឋាភិបាល ទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការខាងវិស័យសង្គមកិច្ច ដែលមិនបានកោះប្រជុំអស់រយៈពេលជាងមួយឆ្នាំមកហើយ។ ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជានៅតែបន្តធ្វើការដោះស្រាយបញ្ហាទាំងនេះតាមរយៈអាណត្តិផ្សេងៗគ្នារបស់ខ្លួន។ បន្ថែមពីលើកង្វល់ដែលមានស្រាប់ទាក់ទងនឹងការគាំពារកុមារ ការប្រព្រឹត្តទៅលើបុគ្គលដែលរស់នៅជាមួយមេរោគអេដស៍/ជម្ងឺអេដស៍ និងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយគ្រោះថ្នាក់ កង្វល់អំពីសុខភាពផ្លូវចិត្ត និងកិច្ចគាំពារចិត្តសាស្រ្តសង្គម ត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំងឡើង តាមរយៈផែនការដែលបានប្រកាសបើកមជ្ឈមណ្ឌលមួយសម្រាប់បុគ្គលដែលមានពិការភាពចិត្តសង្គម ដែលព័ត៌មានលម្អិតអំពីបញ្ហានេះនៅមិនទាន់ត្រូវបានលាតត្រដាងឲ្យដឹងនៅឡើយ។

៧៣. ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិសម្រាប់ឆ្នាំ២០១៦-២០១៨ បានចូលក្នុងឆ្នាំទី២ របស់ខ្លួន។ ក្នុងនាមជាសហប្រធានជាមួយអង្គការសហប្រជាជាតិដើម្បីស្ត្រី (UN-Women) នៃសសរស្តំក្របខ័ណ្ឌស្តីពី "អភិបាលកិច្ច និងសិទ្ធិមនុស្ស" ការិយាល័យOHCHR បានត្រួតពិនិត្យលើការអភិវឌ្ឍនិងការអនុវត្តផែនការការងារប្រចាំឆ្នាំនៃក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDAF) និងធ្វើសេចក្តីរាយការណ៍នាកិច្ចប្រជុំពិនិត្យរបាយការណ៍ប្រចាំឆ្នាំរួមគ្នាជាមួយរដ្ឋាភិបាល ក្នុងខែមីនា ឆ្នាំ២០១៧។

-----------------------------------------------------

[19] សូមមើលរបាយការណ៍លេខ A/HRC/33/39 កថាខណ្ឌទី៨០